# ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

# សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ផលប្រយោជន៍នៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

BENEFITS OF ANALYZING PHNOM PENH WATER SUPPLY AUTHORITY’S FINANCIAL STATEMENTS

## ជំនាញ គណនេយ្យ

**រាជធានីភ្នំពេញ-ឆ្នាំ២០២៥**

PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION YOUTH AND SPORTS
សាកលវិទ្យាល័យវ៉ាន់ដា
VANDA UNIVERSITY

## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ផលប្រយោជន៍នៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

# BENEFITS OF ANALYZING PHNOM PENH WATER SUPPLY AUTHORITY’S FINANCIAL STATEMENTS

គ្រូណែនាំ៖ ហឿង ម៉ុក

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥
PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**
**ប្រធានបទ៖ ផលប្រយោជន៍នៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់**
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

ហឿង ម៉ុក

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅសាកលវិទ្យាល័យវ៉ាន់ដា អស់រយៈពេល៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើនដែលពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យជាពិសេស ក្រុមយើងខ្ញុំបានយល់ច្បាស់ថាជំនាញគណនេយ្យ គឺជាជំនាញមួយដែលមានសារៈសំខាន់ សម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការគណនេយ្យដូចគ្នា។ ដោយឡែកដើម្បីឱ្យការសិក្សារបស់និស្សិត កាន់តែមានគុណភាពខ្ពស់ សាកលវិទ្យាល័យវ៉ាន់ដា បានបញ្ចូលនូវ មុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនិងការងារគណនេយ្យ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទី១ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យបានយល់ច្បាស់ពីការអនុវត្តការងារគណនេយ្យ ពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃ ព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារគណនេយ្យ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតប ឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំង ស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី "**ផលប្រយោជន៍នៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**" យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃការធ្វើម៉ាឃីតធីង។ ក្រុមយើងខ្ញុំសង្ឃឹមថា ការរៀបចំសារណាមួយនេះឡើង និងបានចូលរួមចំណែក មួយក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដទៃទៀតដែលមានគោលបំណង សិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



**ឆី ចាន់មិនា**

ID: B22/817



**ចេង ឡូចលាង**

ID: B22/834



**លី ស្រីនីត**

ID: B22/1185



**គុលា ឌីណា**

ID: B22/1300



**ទូច ស្រីណាន**

ID: B22/1285

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញគណនេយ្យ

**សូមសម្តែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសម្តែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់ខ្ញុំបាទ នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ឌាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំសម្តែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅ ដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យ វ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះលោកគ្រូ **ហឿង ម៉ុក** ជាសាស្ត្រាចារ្យណែនាំ ដោយបានជួយជ្រោមជ្រែង បង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដាទាំងអស់ ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតដល់ធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមយើងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យ នៃសាកលវិទ្យាល័យវ៉ាន់ដា ជំនាន់ទី២២៖

សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទស្តីអំពី "**ផលប្រយោជន៍នៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**" នេះគឺពិតជាស្នាដៃមួយរបស់ក្រុមខ្ញុំបាទ នាងខ្ញុំដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលដែលទាក់ទងទៅនឹងការស្រាវជ្រាវ ដែលបានលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃពុធ ៨កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**



នី ចាន់មិនា

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ក្នុងសម័យប្រកួតប្រជែងខ្ពស់នៃទីផ្សារហិរញ្ញវត្ថុបច្ចុប្បន្ន អាជីវកម្មនីមួយៗត្រូវការឧបករណ៍ក្នុងការត្រួតពិនិត្យ និងវាយតម្លៃលើស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន។ របាយការណ៍ហិរញ្ញវត្ថុគឺជាឧបករណ៍មួយសំខាន់ណាស់សម្រាប់បង្ហាញពីសមត្ថភាពហិរញ្ញវត្ថុ និងសមត្ថភាពប្រតិបត្តិការរបស់ក្រុមហ៊ុន។ ដូចនេះ ការវិភាគរបាយការណ៍ហិរញ្ញវត្ថុអាចជួយដល់ការសម្រេចចិត្តឱ្យមានប្រសិទ្ធភាព។ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ត្រូវបានបង្កើតជាផ្លូវការនៅ ឆ្នាំ1960 ដោយក្រសួងសាធារណការនិងដឹកជញ្ជូន ក្នុងគោលបំណងផ្គត់ផ្គង់ទឹកស្អាតដល់ទីក្រុងភ្នំពេញ។ រដ្ឋាករទឹកគឺជាប្រភពជាតិដ៏សំខាន់មួយ ដែលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច។ សារៈសំខាន់របស់វាមិនត្រឹមតែផ្តល់ទឹកស្អាតប៉ុណ្ណោះទេ ប៉ុន្តែជាជម្រើសសង្គមដើម្បីធានាពីអនាគតនៃសុខភាព បរិស្ថាន និងភាពរីកចម្រើនរបស់ប្រទេស។កត្តាដែលជាចំណុចសំខាន់នៅក្នុងការស្រាវជ្រាវ និងបានធ្វើការចងក្រងសារណាមួយនេះឡើង គឺក្នុងគោលបំណងស្វែងរកពីចំណុចសំខាន់ ផលប្រយោជន៍នៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលធ្វើការវិភាគទៅតាមស្តង់ដា និងរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាករទឹកមានដូចជា របាយការណ៍ តុល្យការ ដែលបង្ហាញនៅស្ថានភាពរបស់ក្រុមហ៊ុន របាយការណ៍លទ្ធផលបានបង្ហាញនៅលទ្ធផលរបស់ក្រុមហ៊ុន។ វិធីសាស្រ្ត ដែលវិភាគទៅតាមស្តង់ដា ហិរញ្ញវត្ថុ មានការវិភាគទៅលើប្រាក់ចំណេញ ការវិភាគហានិភ័យ និងការវិភាគតារាងតុល្យការ។

បន្ទាប់ពីបានសិក្សាស្រាវជ្រាវរួចមក ការវិភាគតាមស្តង់ដារបស់រដ្ឋាករទឹកហើយការវិភាគនេះ រដ្ឋាករទឹកទទួលបានផលប្រយោជន៍វិភាគហិរញ្ញវត្ថុដូចជា បង្កើនប្រសិទ្ធភាពក្នុងការសម្រេចចិត្តរបស់អ្នកគ្រប់គ្រង បង្ហាញពីស្ថានភាពហិរញ្ញវត្ថុជាក់លាក់ ជួយស្វែងរកចំណុចខ្សោយ និងឱកាសសំរាប់ការកែលម្អផ្តល់ទំនុកចិត្តដល់អ្នកវិនិយោគ និងភ្នាក់ងារផ្សេងៗ និងជាឧបករណ៍សម្រាប់ការកំណត់ផែនការយុទ្ធសាស្រ្ត ថែមទាំងជួយការពារអង្គភាពពីហានិភ័យហិរញ្ញវត្ថុថែមទៀតផង។

ជារួម ផលប្រយោជន៍នៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុមានសារសំខាន់ ក្នុងការជួយរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ក្នុងការសម្រេចចិត្តដឹកនាំយ៉ាងមានប្រសិទ្ធភាព ដោយបង្ហាញស្ថានភាពហិរញ្ញវត្ថុជាក់លាក់ ស្វែងរកឱកាសអភិវឌ្ឍ និងការកែលម្អ ការពារពីហានិភ័យ និងបង្កើនទំនុកចិត្តពីភាគីក្រៅ។ វាជាជំហានមូលដ្ឋានសម្រាប់បង្កើតយុទ្ធសាស្រ្តអាជីវកម្ម និងបន្តការអភិវឌ្ឍយ៉ាងចីរភាពនៅក្នុងទីផ្សារកម្ពុជា ដែលមានការប្រកួតប្រជែងខ្លាំង។

# មាតិកា

ទំព័រ


អារម្ភកថា ................................................ i
របានាសម្ព័នក្រុម ................................................ ii
សេចក្តីថ្លែងអំណរគុណ ................................................ iii
អំណះអំណាង ................................................ iv
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ................................................ v
មាតិកា ................................................ vi


## ជំពូកទី១
## សេចក្តីផ្តើម


១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ................................................ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ................................................ ២
១.៣ គោលបំណងនៃការស្រាវជ្រាវ ................................................ ២
១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ................................................ ២
    ១.៤.១ ទំហំដែនកំណត់ ................................................ ២
    ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ................................................ ២
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ................................................ ៣
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ................................................ ៣
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ................................................ ៤


## ជំពូកទី២
## ផលប្រយោជន៍នៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុ


២.១ លក្ខណៈទូទៅនៃហិរញ្ញវត្ថុ ................................................ ៥
    ២.១.១ និយមន័យហិរញ្ញវត្ថុ ................................................ ៥
    ២.១.២ ប្រវត្តិរបស់ហិរញ្ញវត្ថុ ................................................ ៥
    ២.១.៣ ទ្រឹស្តីរបស់ហិរញ្ញវត្ថុ ................................................ ៦
២.២ វិធីសាស្ត្រសម្រាប់វិភាគរបាយការណ៍ហិរញ្ញវត្ថុ ................................................ ៧
    ២.២.១ និយមន័យរបាយការណ៍ហិរញ្ញវត្ថុ ................................................ ៧
    ២.២.២ ប្រភេទនៃរបាយកាណ៍ហិរញ្ញវត្ថុ ................................................ ៧
២.៣ ផលប្រយោជន៍នៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុ ................................................ ៨
    ២.៣.១ និយមន័យការវិភាគរបាយការណ៍ហិរញ្ញវត្ថុ ................................................ ៨
    ២.៣.២ ដំណើរការនៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុ ................................................ ៩

## ជំពូកទី៣

## ផលប្រយោជន៍នៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ


៣.១ ស្ថានភាពទូទៅរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ..... ១០
៣.១.១ ប្រវត្តិរបស់អង្គភាព ..... ១០
៣.១.២ បេសកកម្ម ទស្សនវិស័យ និងគោលដៅរបស់អង្គភាព ..... ១១
៣.១.៣ រចនាសម្ព័ន្ធរបស់អង្គភាព ..... ១២
៣.១.៤ សមាសធាតុរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាព ..... ១២
៣.២ វិធីសាស្ត្រសម្រាប់វិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ..... ១៦
៣.២.១ អនុបាតនៃលទ្ធភាពទូទាត់បំណុលរយៈខ្លី ..... ១៦
ក. អនុបាតចរន្ត ..... ១៧
ខ. អនុបាតរហ័ស ..... ១៧
គ. អនុបាតសាច់ប្រាក់ ..... ១៨
៣.២.២ អនុបាតនៃលទ្ធភាពទូទាត់បំណុលរយៈពេលវែង. ..... ១៩
ក. អនុបាតបំណុលសរុប ..... ១៩
ខ. អនុបាតបំណុលធៀបនឹងមូលធន ..... ២០
គ. មេគុណមូលធន ..... ២០
៣.២.៣ អនុបាតនៃលទ្ធភាពស្វែងរកប្រាក់ចំណេញ ..... ២១
ក. អនុបាតចំណេញដុល ..... ២១
ខ. អនុបាតនៃចំណេញលើទ្រព្យសកម្ម ..... ២២
គ. អនុបាតចំណេញលើមូលធន ..... ២២
៣.៣ ផលប្រយោជន៍នៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ..... ២៣
៣.៣.១ លទ្ធផលប្រតិបត្តិការ ..... ២៣
៣.៣.២ វាយតម្លៃការអនុវត្តន៍ ..... ២៥
៣.៣.៣ ការវិនិយោគ ..... ២៦


## ជំពូកទី៤

## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ


៤.១ ការវិភាគលើចំណុចខ្លាំង ..... ២៨
៤.២ ការវិភាគលើចំណុចខ្សោយ ..... ២៩


## ជំពូកទី៥

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍


៥.១ សេចក្តីសន្និដ្ឋាន ..... ៣០
៥.២ ការផ្តល់អនុសាសន៍ ..... ៣១

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ការធ្វើអាជីវកម្មមិនថារយៈពេលខ្លី ឬរយៈពេលវែងសំខាន់ឬមិនសំខាន់ទោះបីជាអាជីវកម្មមានទម្រង់បែបណានោះទេតែងតែមានហិរញ្ញវត្ថុនៅពីក្រោយជានិច្ច។ ហិរញ្ញវត្ថុ គឺជាអាយុជីវិតនៃអាជីវកម្មណាមួយ។ បើគ្មានហិរញ្ញវត្ថុអង្គភាពនឹងគាំងឬសកម្មភាពនឹងគ្មានប្រសិទ្ធភាពឬគ្មានគុណភាពទេ។ អ្វីដែលសំខាន់លើសពីនេះទៅទៀត អ្នកគ្រប់គ្រង ឬអ្នកប្រើប្រាស់ផ្សេងៗចាំបាច់ណាស់ត្រូវតែមានជំនាញ និងចំណេះដឹងក្នុងការវិភាគហិរញ្ញវត្ថុផងដែរមុននឹង សម្រេចចិត្តលើហិរញ្ញវត្ថុដែលជាធនធានសំខាន់ជាងគេក្នុងការធ្វើអាជីវកម្ម។ម្យ៉ាងវិញទៀត ការសម្រេចចិត្តផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ គឺជាមុខងារចម្បងទីពីរនៃការសម្រេចចិត្តរបស់អង្គភាពបន្ទាប់ពីមានផែនការអាជីវកម្មរួច។

ដូច្នេះហិរញ្ញវត្ថុពិតជាមានសារៈសំខាន់ណាស់ដែលទាមទារឱ្យអង្គភាពនីមួយៗចាំបាច់ត្រូវគ្រប់គ្រងឱ្យបានល្អ រួមទាំងការវិភាគហិរញ្ញវត្ថុដើម្បីធានានូវស្ថេរភាព ប្រសិទ្ធភាព និងភាពរស់រានរបស់អាជីវកម្មរយៈពេលខ្លីនិងរយៈពេលវែងទាំងអស់នោះ។ នៅក្នុងអង្គភាពមួយ អ្នកគ្រប់គ្រងតែងតែខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយការចំណាយលើលទ្ធកម្មហិរញ្ញវត្ថុ និងប្រើប្រាស់វាក្នុងលក្ខណៈចំណេញច្រើនបំផុត។ ដូចនេះការវិភាគហិរញ្ញវត្ថុពិតជាសំខាន់ណាស់ដែលអ្នកគ្រប់គ្រង និងអ្នកប្រើប្រាស់នានាមិនអាចមើលរំលងបានឡើងដើម្បីជំរុញឱ្យគោលដៅនៃការធ្វើអាជីវកម្មមានប្រសិទ្ធភាពនិងប្រសិទ្ធផលក្នុងការផលិតឱ្យបាននូវទ្រព្យនិងប្រាក់ចំណេញជាអតិបរមា។

ដោយមើលឃើញពីសារៈសំខាន់ដែលបានរៀបរាប់ខាងលើ ទើបក្រុមនាងខ្ញុំសម្រេចជ្រើសរើសប្រធានបទមួយស្តីពី "**ផលប្រយោជន៍នៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**" និងរៀបចំជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) ត្រូវបានបង្កើតឡើងជាគ្រឹះស្ថានសាធារណៈ ដែលមានលក្ខណៈសេដ្ឋកិច្ច ស្ថិតក្រោមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ។ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ រ.ទ.ស.ភ បានចុះបញ្ជីជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដោយបានបោះផ្សាយលក់មូលបត្រជាសាធារណៈចំនួន ១៣.០៤៥.៩៧៥ ភាគហ៊ុន ដែលស្មើនឹង ១៥% នៃចំនួនភាគហ៊ុនធម្មតាសរុប។ រ.ទ.ស.ភ បានប្តេជ្ញាចិត្តបន្តធ្វើឱ្យសេវាផ្គត់ផ្គង់ទឹកស្អាតរបស់ខ្លួនមានការរីកចម្រើនប្រកបដោយចេរភាព ព្រមទាំងធ្វើជាអ្នកផ្តល់ប្រឹក្សា ជាអ្នកសម្របសម្រួល ដើម្បីឱ្យប្រជាពលរដ្ឋរស់នៅក្នុងទីប្រជុំជន ខេត្ត-ក្រុងនៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋរស់នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងពិភពលោកមានទឹកស្អាតប្រើប្រាស់ទាំងអស់គ្នា។ អាស្រ័យហេតុនេះហើយ ទើបធ្វើឱ្យក្រុមយើងខ្ញុំសម្រេចចិត្តធ្វើការសិក្សាស្រាវជ្រាវទៅលើ **ផលប្រយោជន៍នៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ** ឱ្យកាន់តែស៊ីជម្រៅ។

នៅក្នុងការស្រាវជ្រាវនេះដែរក្រុមយើងខ្ញុំនិងផ្តោតទៅលើសំណួរពីរគឺ៖

១.តើវិធីសាស្ត្រក្នុងការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញមានអ្វីខ្លះ ?

២.តើការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញមានផលប្រយោជន៍អ្វីខ្លះ ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ក្នុងកិច្ចការស្រាវជ្រាវនេះត្រូវបានរៀបរៀងឡើងក្នុងគោលបំណងដូចខាងក្រោម៖

- ស្វែងយល់ពីស្ថានភាពទូទៅរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ។
- សិក្សាលើព័ត៌មានក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ។
- វិធីសាស្ត្រក្នុងការវិភាគរបាយការណ៍ហិរញ្ញវត្ថុ។
- ស្វែងយល់ពីផលប្រយោជន៍នៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុ។
- ស្វែងយល់អំពីការវាយតម្លៃទៅលើ ចំណុចខ្លាំងនិងចំណុចខ្សោយ។
- ប្រៀបធៀបទ្រឹស្តីដែលធ្លាប់បានសិក្សាកន្លងមកជាមួយនឹងការអនុវត្តជាក់ស្តែង។
- ស្វែងយល់អំពីការធ្វើសេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាសន៍។

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំដែនកំណត់

ការសិក្សាស្រាវជ្រាវនេះ គឺបានសិក្សាទៅប្រធានបទ ផលប្រយោជន៍នៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានទីតាំងនៅអគារលេខ 649 តីវិថីព្រះស៊ីវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញព្រះរាជាណាចក្រកម្ពុជា។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

អាស្រ័យដោយវិសាលភាពនៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុមានលក្ខណៈទូលំទូលាយក៏ដូចជាទំហំពេលវេលាក៏មានពេលកំណត់ហេតុដូច្នេះពួកខ្ញុំសូមលើកយករបាយការណ៍ចន្លោះឆ្នាំ២០២៣ និង ២០២៤ តែប៉ុណ្ណោះ។ ដោយផ្តោតលើការវិភាគពិលទ្ធភាពសងបំណុលរយះពេលខ្លី និងរយះពេលវែងដោយប្រើវិធីសាស្ត្រ Activities ratio និង Profitability ratio ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ បានប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យ សម្រាប់រៀបរាប់ពីផលប្រយោជន៍នៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានទីតាំងនៅអគារលេខ 649 តីវិថីព្រះស៊ីវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ ហើយការប្រមូលទិន្នន័យធ្វើឡើងដោយផ្អែក សំណួរពីរខាងលើ។

**សម្រាប់សំណួរស្រាវជ្រាវទី១៖** ពាក់ព័ន្ធទៅនឹងការសិក្សាស្រាវជ្រាវនេះ គឺប្រមូលទិន្នន័យតាមបែប គុណវិស័យដោយធ្វើឡើងតាមរយៈការដកស្រង់ទិន្នន័យដែលមានស្រាប់តាមរយៈគេហទំព័រផ្លូវការរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានទីតាំងនៅអគារលេខ 649 តីវិថីព្រះស៊ីវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញព្រះរាជាណាចក្រកម្ពុជា។ ដើម្បីផ្តល់ជាព័ត៌មានសម្រាប់អ្នកប្រើប្រាស់និងអ្នកវិនិយោគនានា យកទៅធ្វើការវិភាគ វាយតម្លៃ និង ធ្វើការសម្រេចចិត្តលើផ្នែកហិរញ្ញវត្ថុ ក្នុងគោលបំណងឱ្យដោលដៅរបស់អាជីវកម្មទទួលបានលទ្ធផល ហើយមានប្រសិទ្ធភាព។

**សម្រាប់សំណួរស្រាវជ្រាវទី២៖** ពាក់ព័ន្ធទៅនឹងការសិក្សាស្រាវជ្រាវនេះ គឺប្រមូលទិន្នន័យតាមបែប គុណវិស័យដូចសំណួរទី១ខាងលើដែរ (ផ្តោតទៅលើផលប្រយោជន៍ជាចម្បងនៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុ) ដែលមានសារៈសំខាន់ដល់អ្នកប្រើប្រាស់នានាដូចជា៖ អ្នកធ្វើអាជីវកម្ម អ្នកសិក្សា អ្នកវិនិយោគ អ្នកវិភាគវាយតម្លៃហិរញ្ញវត្ថុ និងអ្នកសេដ្ឋកិច្ចទូទៅ ដើម្បីរៀបចំគោលនយោបាយដើម្បីទប់ស្កាត់ ហានិភ័យលើ សកម្មភាពហិរញ្ញវត្ថុ ក្នុងគោលបំណងធានាបាននូវស្ថេរភាព ប្រសិទ្ធភាព និងភាពរស់រានរបស់អាជីវកម្ម។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

### ក. សម្រាប់បុគ្គល

សម្រាប់បុគ្គលម្នាក់ៗ ការស្រាវជ្រាវមានសារៈសំខាន់យ៉ាងខ្លាំង ក្នុងការបង្កើនសមត្ថភាពផ្ទាល់ខ្លួន និងជួយឱ្យមានការអភិវឌ្ឍយល់ដឹងជាបន្តបន្ទាប់។ វាជួយឱ្យបុគ្គលមានជំនាញគិតវិភាគ ចេះស្វែងរកព័ត៌មានបានត្រឹមត្រូវ និងអាចសម្រេចចិត្តបានយ៉ាងឆ្លាតវៃ។

បុគ្គលដែលអនុវត្តន៍ការស្រាវជ្រាវជាប្រចាំ អាចក្លាយជាមនុស្សចេះបើកចិត្តទូលាយ ងើបឈរដោះស្រាយបញ្ហាបានដោយឯករាជ្យ និងមានទំនួលខុសត្រូវខ្ពស់លើសកម្មភាពរបស់ខ្លួន។ លើសពីនេះ ការស្រាវជ្រាវក៏ជួយបង្កើនទំនុកចិត្ត និងឱកាសជោគជ័យក្នុងអាជីព និងជីវិតផងដែរ។

### ខ. សម្រាប់ស្ថាប័ន

ស្ថាប័នទាំងអស់ មិនថាជាស្ថាប័នរដ្ឋឬឯកជន ក៏មានតម្រូវការក្នុងការស្រាវជ្រាវដែរ ដើម្បីបង្កើនប្រសិទ្ធភាពនៃការងារ និងអភិវឌ្ឍយុទ្ធសាស្ត្រយ៉ាងមានប្រសិទ្ធភាព។ ការស្រាវជ្រាវជួយឱ្យស្ថាប័នទទួលបានព័ត៌មាន និងទិន្នន័យត្រឹមត្រូវសម្រាប់ដំណោះស្រាយបញ្ហា ការប្រកួតប្រជែង និងការបង្កើតអត្ថប្រយោជន៍ថ្មីៗ។

លើសពីនេះ ការស្រាវជ្រាវអាចជាឧបករណ៍សំខាន់សម្រាប់៖

- ការកំណត់គោលនយោបាយ និងផែនការ
- ការផលិតផលិតផលឬសេវាកម្មថ្មីៗ
- ការបង្កើនសមត្ថភាពបុគ្គលិក និងការបណ្តុះបណ្តាល
- ការសិក្សាផលប៉ះពាល់នានា និងគ្រប់គ្រងហានិភ័យ
- ការកែលម្អប្រព័ន្ធគ្រប់គ្រង និងធ្វើឱ្យស្ថាប័នមានភាពរឹងមាំ

### គ. សម្រាប់សង្គមជាតិ

សម្រាប់សង្គមជាតិទាំងមូល ការស្រាវជ្រាវពិតជាមានសារៈសំខាន់ណាស់ ក្នុងការជម្រុញការអភិវឌ្ឍដល់គ្រប់វិស័យ។ វាជាគ្រឹះសំខាន់សម្រាប់ការកសាងសង្គមដដែលមានចំណេះដឹង បច្ចេកវិទ្យា និងគុណភាពជីវិតកាន់តែល្អប្រសើរ។ ការស្រាវជ្រាវនេះជួយដល់ការសម្រេចគោលនយោបាយសាធារណៈប្រកបដោយការយល់ឃើញជាក់ស្តែង និងការគ្រប់គ្រងធនធានជាតិឱ្យមានប្រសិទ្ធភាព។

អត្ថប្រយោជន៍សំខាន់ៗរួមមាន៖

- ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងបង្កើតឱកាសការងារ
- កែលម្អប្រព័ន្ធសុខាភិបាល អប់រំ និងបរិស្ថាន
- ជួយក្នុងការចងក្រងច្បាប់ និងគោលនយោបាយសុទ្ធិតិ

- បង្កើតសង្គមដែលមានវិស័យជំនាញខ្ពស់ និងការចូលរួមសកម្មពីពលរដ្ឋ
- បង្កើនសមត្ថភាពប្រទេសក្នុងការប្រកួតប្រជែងនានានៅអន្តរជាតិ

ដោយសារហេតុដូចខាងលើ ការស្រាវជ្រាវគឺជាគន្លងសំខាន់សម្រាប់ការកសាងសង្គមជាតិឱ្យរឹងមាំ មានសន្តិភាព និងមានអភិវឌ្ឍន៍ប្រកបដោយចីរភាព។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃរបាយការណ៍នេះមានលក្ខណៈដូចខាងក្រោម៖

**ជំពូកទី ១ (សេចក្តីផ្តើម)** បង្ហាញអំពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហា គោលបំណង ដែនកំណត់ វិសាលភាព វិធីសាស្ត្រ និងសារៈសំខាន់នៃការស្រាវជ្រាវ។

**ជំពូកទី ២ (រំលឹកទ្រឹស្តី)** បង្ហាញពីនិយមន័យ ប្រវត្តិទូទៅដែលពាក់ព័ន្ធ និងទ្រឹស្តីរបស់អ្នកប្រាជ្ញដែលពាក់ព័ន្ធនឹងការសិក្សាស្រាវជ្រាវ ។

**ជំពូកទី៣ (ផលប្រយោជន៍នៃការវិភាគលើរបាយការណ៍ហិរញ្ញវត្ថុ)** បង្ហាញពីការស្រាវជ្រាវវិភាគរបាយការណ៍ហិរញ្ញវត្ថុនៅក្នុង រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ គោលនយោបាយ ទស្សនវិស័យ និងបេសកកម្ម គោលដៅ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ។

**ជំពូកទី៤ (ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ)** បង្ហាញពីការវិភាគ និងធ្វើការស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ប្រធានបទដែលពាក់ព័ន្ធ។

**ជំពូកទី៥ (សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍)** សន្និដ្ឋានទៅលើចំណុចទាំងអស់ដែលនៅក្នុងអត្ថបទ និងផ្តល់អនុសាសន៍ទៅលើចំណុចដែលមានកង្វះខាតដើម្បីធ្វើការកែលម្អ ។

# ជំពូកទី២
# ផលប្រយោជន៍នៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុ

## ២.១ លក្ខណៈទូទៅនៃហិរញ្ញវត្ថុ

### ២.១.១ និយមន័យហិរញ្ញវត្ថុ

**ហិរញ្ញវត្ថុ** គឺជាពាក្យទូលំទូលាយដែលរួមបញ្ចូលការ គ្រប់គ្រង និងការវិនិយោគលុយដើម្បីរក្សាវា បង្កើនវា ឬដឹកនាំការប្រើប្រាស់របស់វា។ បុគ្គល ក្រុមហ៊ុន និង រដ្ឋាភិបាលទាំងអស់ចូលរួមក្នុងផ្នែកហិរញ្ញវត្ថុ នៅពេលដែលពួកគេដាក់ប្រាក់របស់ពួកគេដើម្បីធ្វើការ[1]។

**ហិរញ្ញវត្ថុ** ជាមុខវិជ្ជានៃការសិក្សា គឺជាមុខវិជ្ជានៃ ការគ្រប់គ្រងពាណិជ្ជកម្ម ដែលសិក្សាពីការធ្វើផែនការ ការរៀបចំ ការដឹកនាំ និងការគ្រប់គ្រងធនធានរបស់អង្គការដើម្បីសម្រេចបាននូវគោលដៅរបស់វា។ ដោយផ្អែកលើវិសាលភាពនៃសកម្មភាពហិរញ្ញវត្ថុនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ វិន័យអាចបែងចែកទៅជា ហិរញ្ញវត្ថុផ្ទាល់ខ្លួន ក្រុមហ៊ុន និងហិរញ្ញវត្ថុសាធារណៈ[2]។

### ២.១.២ ប្រវត្តិរបស់ហិរញ្ញវត្ថុ

ហិរញ្ញវត្ថុ បានកើតឡើងជាការសិក្សាទ្រឹស្តី និងការអនុវត្តខុសពីវិស័យសេដ្ឋកិច្ចក្នុងទសវត្សរ៍ឆ្នាំ១៩៤០ និងឆ្នាំ១៩៥០។ វាបានចាប់ផ្តើមជាមួយនឹងស្នាដៃរបស់ Harry Markowitz, William F. Sharpe, Fischer Black, និង Myron Scholes ។

វិស័យហិរញ្ញវត្ថុជាពិសេសដូចជា ធនាគារ ការផ្តល់ប្រាក់កម្ចី និងការវិនិយោគ បានកើតឡើងក្នុងទម្រង់មួយចំនួនចាប់តាំងពីពេលព្រឹកព្រលឹមនៃអរិយធម៌។ ប្រតិបត្តិការហិរញ្ញវត្ថុរបស់ជនជាតិ Sumerians ដើមដំបូងត្រូវបានបង្កើតឡើងជាផ្លូវការនៅក្នុងកូដ Babylonian of Hammurabi ប្រហែលឆ្នាំ១៨០០ មុនគ.ស.។ សំណុំនៃច្បាប់នេះគ្រប់គ្រងកម្មសិទ្ធិ ឬការជួលដី ការងារកសិកម្ម និងឥណទាន។

អត្រាការប្រាក់ប្រែប្រួលអាស្រ័យលើថា តើអ្នកកំពុងខ្ចីគ្រាប់ធញ្ញជាតិឬប្រាក់។ សំបក Cowrie ត្រូវបានគេប្រើជាទម្រង់នៃប្រាក់នៅប្រទេសចិននៅឆ្នាំ១២០០ មុនគ.ស.។ Coinage ត្រូវបានណែនាំនៅក្នុងសហសវត្សរ៍ទីមួយមុនគ.ស. ស្តេច Croesus នៃលីឌា ដែលឥឡូវជាប្រទេសទួរគី គឺជាអ្នកដំបូងគេដែលធ្វើកូដកម្ម និងចរាចរកាក់មាសនៅប្រហែលឆ្នាំ ៥៦៤ មុនគ.ស.។ ដូច្នេះពាក្យថា "សម្បូរបែបដូច Croesus" ។ កាក់ត្រូវបានរក្សាទុកនៅក្នុងបន្ទប់ក្រោមដីនៃប្រាសាទនានា ក្នុងទីក្រុងរ៉ូមបុរាណ ដោយសារបូជាចារ្យ និងកម្មករព្រះវិហារត្រូវបានចាត់ទុកថាជាមនុស្សស្មោះត្រង់បំផុត និងលះបង់ដើម្បីការពារទ្រព្យសម្បត្តិ។ ប្រាសាទក៏បានខ្ចីលុយដែរ ដោយដើរតួជាមជ្ឈមណ្ឌលហិរញ្ញវត្ថុនៃទីក្រុងធំៗ។

ភាគហ៊ុនដំបូង ប័ណ្ណបំណុល និងជម្រើស បែលហ្ស៊ិកអះអាងថាជាកន្លែងនៃការដោះដូរលើកដំបូងដោយមួយនៅទីក្រុង Antwerp មានអាយុកាលតាំងពីឆ្នាំ ១៥៣១។ ក្រុមហ៊ុន East India Co. បានក្លាយជាក្រុមហ៊ុនជួញដូរសាធារណៈដំបូងគេក្នុងទសវត្សរ៍ឆ្នាំ១៦០០ ខណៈដែលខ្លួនបានចេញភាគហ៊ុន និងបង់ភាគលាភ លើប្រាក់ចំណូលពីការធ្វើដំណើររបស់ខ្លួន។ សារហ៊ុនទីក្រុងឡុង ដ៏ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៧៧៣

[1] Investopedia. (2025, July 23). *What Is Finance?* Retrieved from https://www.investopedia.com/terms/f/finance.asp
[2] Wikipedia. Adam Hayes. (2020, December 19). *Finance*. Retrieved from https://share.google/PlV3JyWZYpzvb7GYt

ហើយត្រូវបានបន្តដោយផ្សារហ៊ុនញូវយ៉កតិចជាង ២០ ឆ្នាំក្រោយមក។ London Exchange មានតាំងពីទសវត្សរ៍ឆ្នាំ១៥៧០ ជា Royal Exchange។

មូលបត្របំណុល ដែលបានកត់ត្រាដំបូងបំផុតមានតាំងពីឆ្នាំ២៤០០ មុនគ.ស។ វាជាបន្ទះថ្មដែលកត់ត្រាកាតព្វកិច្ចបំណុលដែលជានាការសងគ្រាប់ធញ្ញជាតិ។ រដ្ឋាភិបាល បានចាប់ផ្តើមចេញបំណុលដើម្បីផ្តល់មូលនិធិដល់កិច្ចខិតខំប្រឹងប្រែងសង្គ្រាមក្នុងអំឡុងពេលមជ្ឈិមសម័យ។ ធនាគារអង់គ្លេសត្រូវបានបង្កើតឡើងដើម្បីផ្តល់ហិរញ្ញប្បទានដល់កងទ័ពជើងទឹកអង់គ្លេសក្នុងទសវត្សរ៍ឆ្នាំ១៦០០។ សហរដ្ឋអាមេរិកបានចាប់ ផ្តើមចេញប័ណ្ណរតនាគារដើម្បីគាំទ្រសង្គ្រាមបដិវត្តន៍ជិតមួយសតវត្សក្រោយមក។

ការអនុវត្តដំបូងនៃជម្រើសត្រូវបានគូសបញ្ជាក់តាមរយៈរឿងខ្លីមួយ ដោយទស្សនវិទូ Thales នៅក្នុងការងារទស្សនវិជ្ជាសតវត្សទី៤ របស់អារីស្តូត "នយោបាយ" ។ លោក Thales បានទទួលសិទ្ធិជាមុននូវសិទ្ធិលើដំណាំអូលីវទាំងអស់នៅ Chios និង Miletus ដោយជឿថាការប្រមូលផលផ្លែអូលីវដ៏អស្ចារ្យនឹងមកដល់ក្នុងឆ្នាំខាងមុខនេះ។ ទាំងកិច្ចសន្យាទៅមុខ និងជម្រើសត្រូវបានដាក់បញ្ចូលទៅក្នុងដំណើរការបោសសម្អាតដ៏ទំនើបរបស់ទីក្រុង Amsterdam នៅពាក់កណ្តាលសតវត្សទី១៧។ ការប្រាក់រួម គឺជាការប្រាក់ដែលត្រូវបានគណនាមិនត្រឹមតែលើប្រាក់ដើមប៉ុណ្ណោះទេ ប៉ុន្តែលើការប្រាក់ដែលបានបង្គរពីមុន។ វាត្រូវបានគេស្គាល់ចំពោះអរិយធម៌បុរាណ។ ជនជាតិបាប៊ីឡូនមានឃ្លាមួយសម្រាប់ "ចំណាប់អារម្មណ៍លើចំណាប់អារម្មណ៍" ដែលកំណត់និយមន័យជាមូលដ្ឋាន។ ប៉ុន្តែវាមិនមែនរហូតដល់យុគសម័យមជ្ឈិមសម័យទេដែលអ្នកគណិតវិទូចាប់ផ្តើមវិភាគដើម្បីបង្ហាញពីរបៀបដែលផលបូកដែលបានវិនិយោគអាចកើនឡើង។

ប្រភពដំបូងបំផុត និងសំខាន់បំផុតមួយគឺសាត្រាស្លឹករឹតនព្វន្ធដែលសរសេរដោយLeonardo Fibonacci នៃ Pisa ដែលត្រូវបានគេស្គាល់ថា "Liber Abaci" ក្នុងឆ្នាំ១២០១។ វាផ្តល់នូវឧទាហរណ៍ប្រៀបធៀបការផ្សំនិងការចាប់អារម្មណ៍សាមញ្ញ។ Luca Pacioli's "Summa de arithmetica, geometria, proportioni et proportionalita" របស់ Luca Pacioli គឺជាសន្និសញ្ញាដ៏ទូលំទូលាយដំបូងគេស្តីពីការកត់ត្រា និងគណនេយ្យ។ វាត្រូវបានបោះពុម្ពនៅទីក្រុង Venice ក្នុងឆ្នាំ១៤៩៤ ។

សៀវភៅស្តីពីគណនេយ្យ និងនព្វន្ធដែលសរសេរដោយលោក William Colson បានបង្ហាញខ្លួននៅឆ្នាំ១៦១២ ដែលមានតារាងដំបូងបំផុតនៃការចាប់អារម្មណ៍ដែលសរសេរជាភាសាអង់គ្លេស។ Richard Witt បានបោះពុម្ព "សំណួរនព្វន្ធ" របស់គាត់នៅទីក្រុងឡុងដ៍មួយឆ្នាំក្រោយមក ក្នុងឆ្នាំ១៦១៣ ហើយការប្រាក់រួមត្រូវបានទទួលយកយ៉ាងហ្មត់ចត់។

ការគណនាការប្រាក់ ត្រូវបានរួមបញ្ចូលជាមួយនឹងអត្រារស់រានមានជីវិតអាស្រ័យលើអាយុ ដើម្បីបង្កើតប្រាក់បំណាច់ជីវិតដំបូងនៅក្នុងប្រទេសអង់គ្លេស និងហូឡង់ ឆ្ពោះទៅចុងបញ្ចប់នៃសតវត្សទី១៧[3]។

**២.១.៣ ទ្រឹស្តីរបស់ហិរញ្ញវត្ថុ**

ទ្រឹស្តីហិរញ្ញវត្ថុ ត្រូវបានសិក្សា និងបង្កើតនៅក្នុងវិញ្ញាសាគ្រប់គ្រង ( ហិរញ្ញវត្ថុ ) សេដ្ឋកិច្ច គណនេយ្យ និងគណិតវិទ្យាអនុវត្ត ។ នៅក្នុងអរូបីហិរញ្ញវត្ថុ ទាក់ទងនឹងការវិនិយោគ និងការដាក់ពង្រាយទ្រព្យសកម្ម និងបំណុលលើ "លំហ និងពេលវេលា" ។ ពោល គឺការអនុវត្ត ការវាយតម្លៃ និងការបែងចែកទ្រព្យសកម្មនាពេលបច្ចុប្បន្ននេះ ដោយផ្អែកលើហានិភ័យ និងភាពមិនច្បាស់លាស់នៃលទ្ធផលនាពេលអនាគត ខណៈពេលដែល

[3] Investopedia. (2025, July 23). *History of Finance.* Retrieved from https://www.investopedia.com/terms/f/finance.asp

ការបញ្ចូលតម្លៃពេលវេលានៃប្រាក់ឱ្យបានត្រឹមត្រូវ។ ការកំណត់តម្លៃបច្ចុប្បន្ននៃតម្លៃនាពេលអនាគតទាំងនេះ "ការបញ្ចុះតម្លៃ" ត្រូវតែមាន អត្រាបញ្ចុះតម្លៃសមស្របតាមហានិភ័យ ដែលជាការផ្តោតសំខាន់នៃទ្រឹស្តីហិរញ្ញវត្ថុ។ ដោយសារទ្រឹស្តីហិរញ្ញវត្ថុមានឫសគល់នៅក្នុងមុខវិជ្ជាជាច្រើន រួមទាំងគណិតវិទ្យា ស្ថិតិ សេដ្ឋកិច្ច រូបវិទ្យា និង ចិត្តវិទ្យា វាអាចចាត់ទុកថាជាសិល្បៈ និងវិទ្យាសាស្ត្រចម្រុះមួយ ហើយមានការខិតខំប្រឹងប្រែងជាបន្តបន្ទាប់ ដើម្បីរៀបចំបញ្ជីនៃបញ្ហាដែលមិនទាន់ដោះស្រាយនៅក្នុងហិរញ្ញវត្ថុ[4]។

## ២.២ វិធីសាស្ត្រសម្រាប់វិភាគរបាយការណ៍ហិរញ្ញវត្ថុ

### ២.២.១ និយមន័យរបាយការណ៍ហិរញ្ញវត្ថុ

**របាយការណ៍ហិរញ្ញវត្ថុ** (Financial report) គឺជារបាយការណ៍ដែលបង្ហាញ (Disclose) ពីព័ត៌មាននៃលទ្ធផលហិរញ្ញវត្ថុ (Financial result) របស់អង្គភាពក្នុងកំឡុងពេលជាក់លាក់មួយ។ Financial report មានលក្ខណៈជាការតម្រូវទៅតាមកម្រិតនៃការចង់បានរបស់អ្នកប្រើប្រាស់[5]។

### ២.២.២ ប្រវត្តិរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុ គឺមានដើមកំណើតចាប់តាំងពីសតវត្សទី១៥ ដោយការចាប់ផ្តើមនៃប្រព័ន្ធគណនេយ្យទ្វេគូ (Double-entry bookkeeping) ដោយ Luca Pacioli។ គាត់បានបោះពុម្ពសៀវភៅនៅឆ្នាំ ១៤៩៤ ដែលបានពិពណ៌នាពីវិធីគណនេយ្យដែលត្រូវបានប្រើសម្រាប់គ្រប់គ្រងការប្រាក់ និងទ្រព្យសម្បត្តិ។ ប្រព័ន្ធនេះបានក្លាយជាមូលដ្ឋានសម្រាប់ការបង្កើតរបាយការណ៍ហិរញ្ញវត្ថុសម័យទំនើប។

ក្រោយមករបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានអភិវឌ្ឍន៍បន្ថែមទៀតតាមការរីកចម្រើននៃសេដ្ឋកិច្ច និង ពាណិជ្ជកម្ម។ ស្ថាប័នអន្តរជាតិត្រូវបានបង្កើតឡើង ដូចជា IASB និង FASB ដើម្បីបង្កើតស្តង់ដារសម្រាប់របាយការណ៍ហិរញ្ញវត្ថុដូចជា IFRS និង GAAP។

របាយការណ៍ហិរញ្ញវត្ថុទំនើបមានតួនាទីសំខាន់ក្នុងការបង្ហាញស្ថានភាព និងលទ្ធផលប្រតិបត្តិការនៃអាជីវកម្ម ដោយជួយអោយអ្នកគ្រប់គ្រង អ្នកវិនិយោគ និងភាគីពាក់ព័ន្ធផ្សេងទៀតអាចទទួលសេចក្តីសម្រេចយ៉ាងមានមូលដ្ឋាន។ រហូតដល់គណៈកម្មការមូលបត្រ (SEC) តាមរយៈច្បាប់ស្តីពីមូលបត្រឆ្នាំ 1933 និង ច្បាប់ស្តីពីការផ្លាស់ប្តូរមូលបត្រឆ្នាំ1934 បានកំណត់ថាក្រុមហ៊ុនសាធារណៈមានសវនកម្ម របាយការណ៍ហិរញ្ញវត្ថុគ្រាន់តែជាអ្វីដែលក្រុមហ៊ុនមួយចំនួនប្រើដើម្បីទាក់ទាញវិនិយោគិន។

ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីផ្សារហ៊ុនឆ្នាំ1929 គាំង និងវិបត្តិសេដ្ឋកិច្ចធំ ការមិនទុកចិត្តបានកើនឡើងដោយសារតែទិន្នន័យហិរញ្ញវត្ថុដែលបានរៀបចំ[6]។

### ២.២.៣ ប្រភេទនៃរបាយការណ៍ហិរញ្ញវត្ថុ

**ក- Balance Sheet**

Balance Sheet គឺជាតារាង ឬរបាយការណ៍ដែលបង្ហាញអំពីទ្រព្យ (Assets), បំណុល (Liabilities) និងទុន (Equity)។

---

[4] Wikipedia. Adam Hayes. (19 December 2020). *Finance.* Retrieved from https://share.google/PlV3JyWZYpzvb7GYt.

[5] រៀបរៀងដោយនិស្សិត ម៉េង ស្រីកា, ផាន់ ហៀម, មុំ សុធីវណ្ណ, នៅ ស្រីនីត, រឿន ម៉ារ៉ា. (ឆ្នាំ២០២៣). ប្រធានបទ: *ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ*. សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ ជំនាន់ទី២០ នៃវិទ្យាស្ថាន វ៉ាន់ដា ទំព័រទី១០. ភ្នំពេញ។

[6] Wikipedia. MEAGAN GREW. (2025, June 15). *History of Financial Statements*. Retrieved from https://www.investopedia.com/terms/f/financial-statements.asp

**ខ- Income Statement**

Income Statement គឺជារបាយការណ៍ដែលបង្ហាញពីចំណូល ចំណាយ និងលទ្ធផលចំណេញខាតសម្រាប់កំឡុងការិយបរិច្ឆេទណាមួយច្បាស់លាស់។ របាយការណ៍នេះត្រូវបានគេប្រើសម្រាប់វាស់វែងអំពីលទ្ធផលនៃសកម្មភាពអាជីវកម្មដែលបានរកស៊ីមួយគ្រាកន្លងមក។ របាយការណ៍នេះត្រូវបានគេបែងចែកជាពីរផ្នែកធំៗគឺ Operating activities និង Nonoperation activities។

**គ- Statement of Stockholders' Equity**

Statement of Stockholders' Equity គឺជារបាយការណ៍ដែលបង្ហាញពីបម្រែបម្រួលទុនរបស់ភាគហ៊ុនិក ពីដើមគ្រារហូតដល់ចុងគ្រា។

**ឃ- Statement of Cash Flow**

Statement of Cash Flow គឺជារបាយការណ៍ដែលបង្ហាញពីលំហូរសាច់ប្រាក់ហូរចូល និងហូរចេញ។ របាយការណ៍នេះ ត្រូវបានគេបែងចែកជា ៣ផ្នែកគឺសកម្មភាពប្រតិបត្តិការ (Operating Activities) សកម្មភាពវិនិយោគ (Investing Activities) និងសកម្មភាពហិរញ្ញប្បទាន (Financing Activities)។

**ង- Financial Statement**

Balance sheet, income statement, statement of stockholders' Equity និង statement of cash flow គឺជារបាយការណ៍សង្ខេប វាមិនបង្ហាញលំអិតឡើយ ពីសាច់រឿងនៃប្រតិបត្តិការអាជីវកម្ម ដូច្នេះបើអ្នកចង់លំអិតបន្ថែមទៀត អ្នកត្រូវទៅមើលក្នុងរបាយការណ៍កំណត់សម្គាល់[7]។

## ២.៣ ផលប្រយោជន៍នៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុ

### ២.៣.១ និយមន័យការវិភាគរបាយការណ៍ហិរញ្ញវត្ថុ

ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ (Financial statement analysis) គឺជាការសិក្សាអំពីដំណើរការនៃការពិនិត្យ(Reviewing) វិភាគ (Analysis) និងការវាយតម្លៃ(Evaluating) របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដើម្បីយល់ដឹងពីសុខភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន (Financial health of the company) ក្នុងគោលបំណងធ្វើការសម្រេចចិត្តឱ្យកាន់តែមានប្រសិទ្ធភាព[8]។

### ២.៣.២ ដំណើរការនៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុ (The Financial Analysis Process)

ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ ក៏ដូចខាងការងារធុរកិច្ចដទៃទៀតដែរ អ្នកវិភាគចាំបាច់ណាស់ត្រូវកំណត់គោលបំណងឱ្យបានច្បាស់។ ពេលអ្នកកំណត់គោលបំណងបានច្បាស់ហើយ អ្នកក៏អាចកំណត់បានដែរនូវប្រភេទព័ត៌មានដែលចាំបាច់ និងវិធីសាស្ត្រដែលសមស្របសម្រាប់ការវិភាគ។

---

[7] រៀបរៀងដោយនិស្សិត ម៉េង ស្រីកា, ផាន់ ហៀម, មុំ សុជីវណ្ណ, នៅ ស្រីនីត, រឿន ម៉ារ៉ា. (ឆ្នាំ២០២៣). ប្រធានបទ: *ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ*. សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ ជំនាន់ទី២០ នៃវិទ្យាស្ថាន វ៉ាន់ដា ទំព័ទី១០. ភ្នំពេញ។

[8] រៀបរៀងដោយនិស្សិត ម៉េង ស្រីកា, ផាន់ ហៀម, មុំ សុជីវណ្ណ, នៅ ស្រីនីត, រឿន ម៉ារ៉ា. (ឆ្នាំ២០២៣). ប្រធានបទ: *ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ*. សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ ជំនាន់ទី២០ នៃវិទ្យាស្ថាន វ៉ាន់ដា ទំព័ទី៣. ភ្នំពេញ។

ខាងក្រោមនេះគឺជាដំណើរការនៃការវិភាគ៖

Step 1: កំណត់គោលដៅ ឬគោលបំណងនៃការវិភាគ (Identify the goals and objectives of the analysis.)

-វាយតម្លៃក្រុមហ៊ុន (Valuation of the firm)

-វាយតម្លៃសមត្ថភាពសងបំណុលរបស់ក្រុមហ៊ុន (Ability to repay debt)

-គុណភាពនៃការគ្រប់គ្រង (Management Effectiveness)

Step 2: ប្រមូលព័ត៌មានសមរម្យសម្រាប់វិភាគ (Gather appropriate information for analysis)

Step 3: ដំណើរការទិន្នន័យ

-Common-size financial statement

-Ratio, trends and graphs

-Forecasts…

Step 4: វិភាគ/បកស្រាយព័ត៌មានដែលបានដំណើរការដែលប្រើប្រាស់ (analysis tools)

-បកស្រាយព័ត៌មាន

-វិភាគចំណុចខ្លាំងខ្សោយ និង

-វាយតម្លៃ

Step 5: សន្និដ្ឋាន និងផ្តល់អនុសាសន៍

Step 6: តាមដាននូវអ្វីដែលបានអនុវត្តន៍[9]។

[9] រៀបរៀងដោយនិស្សិត គីម ជីត្រូ, ផាន់ សុផានិត, ឌុំ ដេត, លិ ម្លិស, ភី ស៊ីណា. (ឆ្នាំ២០២៤). *ប្រធានបទ: ផលប្រយោជន៍នៃការវិភាគរបាយការណ៍ ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន តូយ៉ូតា*. សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ ជំនាន់ទី២១ នៃវិទ្យាស្ថាន វ៉ាន់ដា ភ្នំពេញ ទំព័រទី១០ សរុប ៣៥ទំព័រ។

# ជំពូកទី៣
# ផលប្រយោជន៍នៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

## ៣.១ ស្ថានភាពទូទៅរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

### ៣.១.១ ប្រវត្តិរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

រដ្ឋាករទឹកភ្នំពេញ បានចាប់បដិសន្ធិឡើងនៅក្នុងឆ្នាំ១៩៥៩ និងដោយមានការតែងតាំងជាផ្លូវការតាមព្រះរាជក្រិត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ ១៦៤នស ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៦០ ជាអង្គភាពផលិតកម្ម និង អាជីវកម្ម របស់រដ្ឋចំណុះផ្ទាល់សាលាក្រុងភ្នំពេញ ហើយដែលបានប្រសិទ្ធនាមជាផ្លូវការថា « រដ្ឋាករទឹកភ្នំពេញ »។ អង្គភាពនេះមានភារកិច្ចផលិតទឹកស្អាត និងផ្គត់ផ្គង់ បំរើសំណូមពរប្រើប្រាស់របស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ ព្រមទាំងធានាគុណភាព ចំណូល-ចំណាយ លើការងារផលិតកម្ម និងវិនិយោគ។ នៅក្នុងអំឡុងឆ្នាំ១៨៩៥ ប្រព័ន្ធផ្គត់ផ្គង់ទឹកសម្រាប់ទីក្រុងភ្នំពេញ ត្រូវបានរៀបចំឡើងជាដំបូងដោយក្រុមហ៊ុនទឹក និងអគ្គិសនី ឥណ្ឌូចិនរបស់បារាំងដែលមានឈ្មោះថា « CEEI » បានវិនិយោគទុនសាងសង់រោងចក្រ ផលិតទឹកជ្រោយចង្វារ ដែលមាន សមត្ថភាព ផលិត ទឹក ជាមធ្យម១៥,០០០ម³/ថ្ងៃ ព្រមទាំងបណ្តាញ ចែក ចាយប្រវែង៤០គីឡូម៉ែត្រ ស្ថិតក្នុងខណ្ឌដូនពេញភាគខាងកើត នៃរាជធានីភ្នំពេញនាពេលបច្ចុប្បន្ន។ ក្នុងអំឡុងពេលនោះ ការងារផ្គត់ផ្គង់ទឹកក្នុងទីក្រុងភ្នំពេញ ត្រូវបានអនុញ្ញាតិឱ្យធ្វើអាជីវកម្ម រកចរិកាចំណូល ដើម្បីធានាដំណើរការផលិត និងវិនិយោគដោយខ្លួនឯង ក្រោមលក្ខខន្តិកៈដោយឡែករបស់ក្រុមហ៊ុនឥណ្ឌូចិនបារាំង។

ចាប់ពីឆ្នាំ១៩៥៧ រហូតដល់ឆ្នាំ១៩៧០ ការងារផ្គត់ផ្គង់ទឹកស្អាត និងដំណើរការអាជីវកម្មរបស់ រដ្ឋាករទឹកភ្នំពេញត្រូវបាន ពង្រីកបន្ថែមដោយការជួសជុល និងបង្កើតរោងចក្រផលិតទឹក និងបណ្តាញចែកចាយថ្មីដូចមានរៀបរាប់ខាងក្រោម៖

(១) ក្នុងឆ្នាំ១៩៥៨ រោងចក្រចំការមន ដែលមានសមត្ថភាពផលិត១០ ០០០ម³/ថ្ងៃ ត្រូវបានសាងសង់ឡើងដោយក្រុមហ៊ុន ដឺក្រេម៉ុង (DEGREMONT)។

(២) ក្នុងឆ្នាំ១៩៥៩ រោងចក្រផលិតទឹកជ្រោយចង្វារ ត្រូវបានជួសជុល និងពង្រីកសមត្ថភាពក្នុងការផលិតបន្ថែមរហូតដល់៤៥ ០០០ម³/ថ្ងៃ។

(៣) ក្នុងឆ្នាំ១៩៦៦ រោងចក្រផលិតទឹកថ្មីមួយ នៅភូមិព្រែក ដែលត្រូវបានសាងសង់ឡើងដោយក្រុមហ៊ុន ពិកចាបាល (PICCHABAL) ដែលមានសមត្ថភាពផលិត១០០ ០០០ម³/ថ្ងៃ។

(៤) ប្រព័ន្ធបណ្តាញចែកចាយទឹក ត្រូវបានជួសជុល និងពង្រីកបន្ថែម ២៤២ម នៅតាមបណ្តាឆ្នាំដូចខាងក្រោម៖

១) ក្នុងឆ្នាំ១៩៥៧ បណ្តាញមេ និងបណ្តាញចែកចាយទឹកប្រវែង ៣៦គីឡូម៉ែត្រ ត្រូវបានដាក់បន្ថែមដោយក្រុមហ៊ុន ដឺក្រេម៉ុង (DEGREMONT)។

២) ក្នុងឆ្នាំ១៩៥៩ បណ្តាញមេ និងបណ្តាញចែកចាយទឹកប្រវែង៣២គីឡូម៉ែត្រ ត្រូវបានដាក់បន្ថែមដោយក្រុមហ៊ុន គូប៊ូតា (KUBUTA)។

៣) ក្នុងឆ្នាំ១៩៦០ បណ្តាញមេ និងបណ្តាញចែកចាយទឹកប្រវែង១៦៥គីឡូម៉ែត្រ ត្រូវបានដាក់បន្ថែមដោយរដ្ឋាករទឹកភ្នំពេញ។

ដោយមានសកម្មភាពការងារជួសជុល និងពង្រីកបន្ថែមប្រព័ន្ធផ្គត់ផ្គង់ខាងលើបានធ្វើឱ្យសមត្ថភាពផលិតទឹកសរុបកើនឡើងដល់២៥ ០០០ម³/ថ្ងៃ ក្នុងឆ្នាំ១៩៥៩ ដល់៥៥ ០០០ម³/ថ្ងៃ ក្នុងឆ្នាំ១៩៦៣ និង ១៥៥ ០០០ ម³/ថ្ងៃ ក្នុងឆ្នាំ១៩៦៦។ ការគ្រប់គ្រងអតិថិជនត្រូវបានពង្រឹង និងពង្រីកឱ្យកាន់តែប្រសើរឡើងជាលំដាប់ ធ្វើអោយការងារអាជីវកម្មអាចរកចំណូលបានច្រើន និងធានាចំណាយសម្រាប់ដំណើរការផលិតនិងផ្គត់ផ្គង់ទឹកដោយពុំចាំបាច់មានជំនួយពីខាងក្រៅ។

ឆ្លងកាត់ការវិវត្តន៍ឥតឈប់ឈរពីសម័យកាលមួយទៅសម័យកាលមួយ ទើបនៅឆ្នាំ១៩៩៦ អង្គភាពនេះត្រូវបានប្រកាស់តែងតាំងដោយប្រសិទ្ធនាមជាថ្មីថា «រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ» ដែលជាគ្រឹះស្ថានសាធារណៈមួយមានចរិកជាគ្រឹះស្ថានឧស្សាហកម្ម និងពាណិជ្ជកម្ម តាមអនុក្រិតលេខ០៦៩៦/០៣ ចុះនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ « រ.ទ.ស.ភ » គឺជាសហគ្រាសនិតិបុគ្គលប្រកបដោយស្វ័យភាពផ្នែករដ្ឋបាល និងផ្នែកហិរញ្ញវត្ថុ។ អង្គភាពនេះមានភារកិច្ចសំខាន់ដូចខាងក្រោម៖

(១) ផលិត និងផ្គត់ផ្គង់ទឹកស្អាត សម្រាប់បម្រើសំណូមពរប្រើប្រាស់នៃប្រជាពលរដ្ឋនៅក្នុងទីក្រុងភ្នំពេញទាំងមូល។

(២) ធានាលើតុល្យភាពចំណូល និងចំណាយទាំងអស់ចំពោះដំណើរការផលិតកម្ម និងវិនិយោគនៅក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួនដោយត្រូវប្រៀកាន់ភ្ជាប់នូវគោលការណ៍ និងរបៀបប្រកបកិច្ចការដូចគ្នាទៅនឹងពាណិជ្ជកម្មទូទៅ។

ក្នុងន័យនេះ រ.ទ.ស.ភ ត្រូវទទួលស្វយ័តភាពយ៉ាងទូលំទូលាយ ដើម្បីដឹកនាំចាត់ចែងសកម្មភាពរបស់ខ្លួនក្នុងគោលបំណងបំពេញបេសកកម្មអោយមានប្រសិទ្ធភាព និងធ្វើយ៉ាងណារក្សាទ្រព្យសម្បត្តិឱ្យបានគង់វង្ស និងលើកកំពស់បញ្ហាអនាម័យសុខភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងសោភណភាព រាជធានីភ្នំពេញ ក៏ដូចជារក្សាអោយមានការអភិវឌ្ឍន៍ និងរីកចំរើនឈានឡើង[10]។

**៣.១.២ ចក្ខុវិស័យ និងបេសកកម្ម**

**ក. ចក្ខុវិស័យ**

រ.ទ.ស.ភ បានប្តេជ្ញាចិត្តបន្តធ្វើឱ្យសេវាផ្គត់ផ្គង់ទឹកស្អាតរបស់ខ្លួនមានការរីកចម្រើនប្រកបដោយចីរភាព ព្រមទាំងធ្វើជាអ្នកផ្តល់ប្រឹក្សា ជាអ្នកសម្របសម្រួល ដើម្បីឱ្យប្រជាពលរដ្ឋរស់នៅក្នុងទីប្រជុំជនខេត្ត-ក្រុងនៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋរស់នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ក្នុងពិភពលោកមានទឹកស្អាតប្រើប្រាស់ទាំងអស់គ្នា។

**ខ. បេសកកម្ម**

បេសកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញគឺ ធានាផ្គត់ផ្គង់ទឹកស្អាតគ្មានមេរោគ ២៤ម៉ោងក្នុងមួយថ្ងៃ និងចុះនួន៧ថ្ងៃក្នុងមួយសប្តាហ៍ មានសម្ពាធគ្រប់គ្រាន់ និងក្នុងតម្លៃមួយសមស្របជូនប្រជាពលរដ្ឋ

[10] រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ. *ប្រវត្តិ*. Retrieved June, 23 2025 from https://www.ppwsa.com.kh/kh/index.php?page=history

ទូទាំងរាជធានីភ្នំពេញ និងទីប្រជុំជនរបស់ខេត្តកណ្ដាលដែលជាប់នឹងរាជ-ធានីភ្នំពេញ ដោយមិនមើលរំលងប្រជាពលរដ្ឋក្រីក្រ។ ក្រៅពីនេះ រ.ទ.ស.ភ បាននិងកំពុងចែករំលែកបទពិសោធន៍ការងាររបស់ខ្លួនដល់បណ្ដារដ្ឋាករទឹក ខេត្ត-ក្រុង មួយចំនួននៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងបណ្ដាអង្គភាពទឹកស្អាតក្នុងតំបន់ និងក្នុងពិភពលោកតាមសំណូមពរ សំដៅសម្រេចបាននូវគោល ដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ក៏ដូចជាគោលដៅ អភិវឌ្ឍន៍សហស្សវត្សរ៍ពិភពលោក។

### ៣.១.៣ រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន



## ៣.១.៤ សមាសធាតុរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាព

### ក. របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

**PHNOM PENH WATER SUPPLY AUTHORITY**
**(Incorporated in Cambodia)**
**STATEMENT OF FINANCIAL POSITION**
**AS AT 31 DECEMBER 2024**

| | Note | 31.12.2024 | 31.12.2023 | 1.1.2023 |
|---|---|---|---|---|
| | | KHR'000 | KHR'000 (restated) | KHR'000 (restated) |
| **ASSETS** | | | | |
| **Non-current assets** | | | | |
| Property, plant and equipment | 5 | 2,939,664,426 | 2,494,501,714 | 2,203,041,914 |
| Intangible assets | 6 | 9,080,507 | 10,463,074 | 12,089,587 |
| | | 2,948,744,933 | 2,504,964,788 | 2,215,131,501 |
| **Current assets** | | | | |
| Inventories | 7 | 144,235,770 | 318,746,592 | 152,737,078 |
| Trade and other receivables | 8 | 27,537,927 | 17,664,096 | 25,377,170 |
| Contract assets | 9 | 37,586,190 | 38,628,477 | 34,925,467 |
| Loan to employees | 10 | 3,894,589 | 7,956,651 | 7,956,651 |
| Short-term investments | 11 | 94,961,360 | 127,316,003 | 126,118,416 |
| Current tax assets | | 3,797,846 | | |
| Cash and bank balances | 12 | 18,406,666 | 23,088,570 | 61,158,915 |
| | | 330,420,348 | 533,400,389 | 408,273,697 |
| **TOTAL ASSETS** | | **3,279,165,281** | **3,038,365,177** | **2,623,405,198** |
| **EQUITY AND LIABILITIES** | | | | |
| **Equity** | | | | |
| Share capital | 13 | 620,759,107 | 620,759,107 | 620,759,107 |
| Reserves | 14 | 713,232,603 | 591,192,666 | 543,268,075 |
| Retained earnings | | 31,080,903 | 72,644,018 | 52,226,195 |
| **TOTAL EQUITY** | | 1,365,072,613 | 1,284,595,791 | 1,216,253,377 |
| **LIABILITIES** | | | | |
| **Non-current liabilities** | | | | |
| Borrowings | 15 | 443,727,099 | 457,818,735 | 986,495,717 |
| Deferred government and other grants | 16 | 72,625,961 | 74,162,746 | 69,238,477 |
| Deferred tax liabilities | 17 | 105,146,861 | 91,994,321 | 77,016,716 |
| Other payables | 18 | 88,950,566 | 82,903,732 | 76,801,705 |
| | | 710,450,487 | 706,879,534 | 1,209,552,615 |
| **Current liabilities** | | | | |
| Trade and other payables | 18 | 213,224,225 | 169,743,640 | 149,890,145 |
| Borrowings | 15 | 986,892,283 | 862,783,350 | 23,499,158 |
| Contract liabilities | 9 | 3,525,673 | 4,254,138 | 4,456,756 |
| Current tax liabilities | | | 10,108,724 | 19,753,147 |
| | | 1,203,642,181 | 1,046,889,852 | 197,599,206 |
| **TOTAL LIABILITIES** | | 1,914,092,668 | 1,753,769,386 | 1,407,151,821 |
| **TOTAL EQUITY AND LIABILITIES** | | **3,279,165,281** | **3,038,365,177** | **2,623,405,198** |

## ខ. របាយការណ៍ចំណេញ ឬ ខាត និងចំណូលពេញលេញផ្សេងៗ

**PHNOM PENH WATER SUPPLY AUTHORITY**
**(Incorporated in Cambodia)**
**STATEMENT OF PROFIT OR LOSS AND OTHER COMPREHENSIVE INCOME**
**FOR THE FINANCIAL YEAR ENDED 31 DECEMBER 2024**

| | **Note** | **2024**<br>**KHR'000** | **2023**<br>**KHR'000**<br>**(restated)** |
|---|---|---|---|
| **Revenue:** | | | |
| Sales | 19 | 317,778,996 | 297,416,141 |
| Construction service fees | 20 | 11,392,112 | 14,854,539 |
| Other income | 21 | 18,526,670 | 21,138,150 |
| | | 347,697,778 | 333,408,830 |
| **Expenses:** | | | |
| Depreciation and amortisation charges | | -59,515,914 | -61,978,134 |
| Electricity costs | | -48,653,063 | -42,291,446 |
| Salaries, wages and related expenses | 22 | -85,552,510 | -80,292,438 |
| Raw materials for water treatment | 23 | -18,976,590 | -15,875,313 |
| Raw materials for household water connections | 24 | -6,293,277 | -4,816,514 |
| Repairs and maintenance | | -14,666,732 | -11,651,058 |
| Construction service expenses | | -8,961,596 | -9,731,518 |
| Reversal of impairment on loan to employees | 10 | 260,874 | |
| Other operating expenses | | -14,136,399 | -15,155,437 |
| Foreign exchange loss - net | 25 | -2,196,121 | -5,856,919 |
| | | -258,691,328 | -247,648,777 |
| Operating profit | | 89,006,450 | 85,760,053 |
| Finance income | 26 | 57,169,387 | 39,038,591 |
| Finance costs | 26 | -39,001,476 | -25,860,597 |
| Profit before tax | | 107,174,361 | 98,938,047 |
| Tax expense | 27 | -22,131,448 | -26,290,475 |
| Profit for the financial year | | 85,042,913 | 72,647,572 |
| Other comprehensive income, net of tax | | | |
| Total comprehensive income for the financial year | | **85,042,913** | **72,647,572** |

Earnings per share (expressed in KHR) attributable to shareholders of the PPWSA during the financial year are as follows:

| | | | |
|---|---|---|---|
| Basic earnings per share | 28 | 977.81 | 835.29 |
| Diluted earnings per share | 28 | **977.81** | **835.29** |

## គ. របាយការណ៍បម្រែបម្រួលមូលធន

**PHNOM PENH WATER SUPPLY AUTHORITY**
**(Incorporated in Cambodia)**
**STATEMENT OF CHANGES IN EQUITY**
**FOR THE FINANCIAL YEAR ENDED 31 DECEMBER 2024**

| | Note | Share capital KHR'000 | Reserves KHR'000 | Retained earnings KHR'000 | Total KHR'000 |
|---|---|---|---|---|---|
| **Balance as at 1 January 2023, as previously reported** | | 620,759,107 | 543,268,075 | 108,185,865 | 1,272,213,047 |
| Prior year adjustments | 37 | | | -55,959,670 | -55,959,670 |
| **Balance as at 1 January 2023, as restated** | | 620,759,107 | 543,268,075 | 52,226,195 | 1,216,253,377 |
| Profit for the financial year, representing total comprehensive income: | | | | | |
| .As previously reported | | | | 126,609,582 | 126,609,582 |
| .Prior year adjustments | 37 | | | -53,962,010 | -53,962,010 |
| As restated | | | | 72,647,572 | 72,647,572 |
| **Transactions with owners** | | | | | |
| Transfer to reserves: | | | | | |
| .As previously reported | 14 | | 103,880,707 | -103,880,707 | |
| .Prior year adjustments | 37 | | -55,956,116 | 55,956,116 | |
| Dividends | 29 | | | -4,305,158 | -4,305,158 |
| Total transactions with owners, as restated | | | 47,924,591 | -52,229,749 | -4,305,158 |
| **Balance as at 31 December 2023/1 January 2024, as restated** | | **620,759,107** | **591,192,666** | **72,644,018** | **1,284,595,791** |
| Profit for the financial year, representing total comprehensive income | | | | 85,042,913 | 85,042,913 |
| **Transactions with owners** | | | | | |
| Transfer to reserves | 14 | | 122,043,491 | -122,043,491 | |
| Dividends | 29 | | | -4,566,091 | -4,566,091 |
| Total transactions with owners | | | 122,043,491 | -126,609,582 | -4,566,091 |
| **Balance as at 31 December 2024** | | **620,759,107** | **713,236,157** | **31,077,349** | **1,365,072,613** |

## ឃ. របាយការណ៍លំហូរសាច់ប្រាក់

**PHNOM PENH WATER SUPPLY AUTHORITY**
**(Incorporated in Cambodia)**
**STATEMENT OF CASH FLOWS**
**FOR THE FINANCIAL YEAR ENDED 31 DECEMBER 2024**

| | **Note** | **2024 KHR'000** | **2023 KHR'000 KHR'000 (restated)** |
|---|---|---|---|
| **Cash flows from operating activities** | | | |
| Profit before tax | | 107,174,361 | 98,938,047 |
| Adjustments for: | | | |
| Amortisation of intangible assets | 6 | 1,157,155 | 1,856,450 |
| Amortisation of deferred government and other grants | 16 | -2,009,908 | -2,009,908 |
| Depreciation of property, plant and equipment | 5 | 58,107,873 | 60,115,369 |
| Finance income | 26 | -57,169,387 | -39,038,591 |
| Finance costs | 26 | 39,001,476 | 25,860,597 |
| Property, plant and equipment written-off | 5 | 365,907 | 1,628,455 |
| Intangible assets written-off | 6 | 250,886 | 6,315 |
| Reversal of impairment on loan to employees | 10 | -260,874 | |
| Operating profit before working capital changes | | 146,617,489 | 147,356,734 |
| Changes in working capital: | | | |
| Inventories | | 130,023,452 | -238,152,938 |
| Trade and other receivables | | -15,084,160 | 8,140,350 |
| Trade and other payables | | -14,746,833 | 12,772,383 |
| Contract assets | | 1,042,287 | -3,703,010 |
| Contract liabilities | | -728,465 | -202,618 |
| Cash generated from/(used in) operations | | 247,123,770 | -73,789,099 |
| Income tax paid | | -19,087,632 | -20,957,293 |
| Net cash from/(used in) operating activities | | 228,036,138 | -94,746,392 |
| **Cash flows from investing activities** | | | |
| Purchase of property, plant and equipment | 5 | -389,896,854 | -256,226,232 |
| Purchase of intangible assets | 6 | -25,474 | -236,252 |
| Interest received | | 8,025,977 | 6,310,491 |
| Withdrawal/(Placement) of short-term investments | | 32,354,643 | -1,197,587 |
| Net cash used in investing activities | | -349,541,708 | -251,349,580 |

**PHNOM PENH WATER SUPPLY AUTHORITY**
**(Incorporated in Cambodia)**
**STATEMENT OF CASH FLOWS**
**FOR THE FINANCIAL YEAR ENDED 31 DECEMBER 2024 (continued)**

| | Note | 2024<br>KHR'000 | 2023<br>KHR'000<br>(restated) |
|---|---|---|---|
| **Cash flows from financing activities** | | | |
| Dividend paid | | -4,566,091 | -4,305,158 |
| Drawdown of borrowings | | 155,911,598 | 341,987,537 |
| Interest paid | | -19,232,563 | -15,111,475 |
| Repayments of borrowings | | -20,085,337 | -21,479,454 |
| Proceed from government grant | 16 | 473,123 | 6,934,177 |
| Proceed from settlement of loan to employee | | 4,322,936 | |
| Net cash from financing activities | | 116,823,666 | 308,025,627 |
| **Net decrease in cash and cash equivalents** | | -4,681,904 | -38,070,345 |
| **Cash and cash equivalents at beginning of financial year** | | 23,088,570 | 61,158,915 |
| **Cash and cash equivalents at end of financial year** | 12 | 18,406,666 | 23,088,570 |

**RECONCILIATION OF LIABILITIES ARISING FROM FINANCING ACTIVITIES**

| | Borrowings<br>(Note 15)<br>KHR'000 |
|---|---|
| **At 1 January 2023** | **1,009,994,875** |
| Cash flows | 320,508,079 |
| Non-cash flows: | |
| .Effect of foreign exchange | -9,967,955 |
| .Accrued interest | 67,086 |
| **At 31 December 2023** | **1,320,602,085** |
| Cash flows | 135,826,261 |
| Non-cash flows: | |
| .Effect of foreign exchange | -25,975,442 |
| .Accrued interest | 166,478 |
| At 31 December 2024 | **1,430,619,382** |

## ៣.២ វិធីសាស្ត្រសម្រាប់វិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

### ៣.២.១ អនុបាតនៃលទ្ធភាពទូទាត់បំណុលរយៈខ្លី (Liquidity ratio)

អនុបាតនៃលទ្ធភាពទូទាត់បំណុលរយៈខ្លី ត្រូវបានគេស្គាល់ថាជាសមាមាត្រសាច់ប្រាក់ងាយស្រួល គឺជារង្វាស់ហិរញ្ញវត្ថុដែលប្រើដើម្បីវាស់ស្ទង់សមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរយៈពេលខ្លីរបស់ខ្លួន។ វាផ្តល់នូវការយល់ដឹងអំពីស្ថិរភាពហិរញ្ញវត្ថុ និងហានិភ័យដែលទាក់ទងនឹងបំណុលបច្ចុប្បន្នរបស់ក្រុមហ៊ុន។ សមាមាត្រត្រូវបានប្រើប្រាស់ជាទូទៅដោយវិនិយោគិន ម្ចាស់បំណុល និងអ្នកវិភាគហិរញ្ញវត្ថុ ដើម្បីវាយតម្លៃសុខភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ ប្រភេទអនុបាត ដែលត្រូវបានប្រើប្រាស់សម្រាប់វាស់វែងលទ្ធភាពក្នុងការទូទាត់បំណុលរយៈពេលខ្លី គឺមានដូចខាងក្រោម៖

**ក. អនុបាតចរន្ត (Current Ratio)**

អនុបាតនេះ ត្រូវបានប្រើប្រាស់វាស់វែងលទ្ធភាពទូទាត់បំណុលរយៈពេលខ្លីជាមួយនឹងទ្រព្យសកម្មរយៈពេលខ្លី។ប្រសិនបើលទ្ធផលនៃអនុបាតនេះមានទំហំធំជាង១ វាបង្ហាញឱ្យឃើញថា ល្បឿននៃចលនាសាច់ប្រាក់នៅក្នុងក្រុមហ៊ុន គឺមានភាពល្អប្រសើ ក៏ប៉ុន្តែប្រសិនបើលទ្ធផលនៃអនុបាតនេះ មានកម្រិតតូចជាង១ វិញនោះវាបង្ហាញថាក្រុមហ៊ុននឹងជួបនូវបញ្ហាហិរញ្ញវត្ថុ។

អនុបាតចរន្តមានរូបមន្តដូចខាងក្រោម៖

$$\text{អនុបាតចរន្ត (Current Ratio)} = \frac{\text{ទ្រព្យចរន្តសរុប (Total Current Assets)}}{\text{បំណុលចរន្តសរុប (Total Current Liabilities)}}$$

តារាងប្រៀបធៀប

| Year | Current Assets | Current Liabilities | Current Ratio | Change |
|---|---|---|---|---|
| 2023 | 533,400,389 | 1,046,889,852 | 0.51 | - |
| 2024 | 330,420,348 | 1,203,642,181 | 0.27 | (24%) |

បកស្រាយ៖ តាមតារាងខាងលើបានបង្ហាញថាផលធៀបរវាងទ្រព្យសកម្មរយៈពេលខ្លី និង បំណុលរយៈពេលខ្លីក្នុងឆ្នាំ២០២៣ ស្មើនឹង០.៥១ មានន័យថាមានចំនួនជិត១ដងនៃបំណុលរយៈពេលខ្លី ក្រុមហ៊ុនមានទ្រព្យសកម្មរយៈខ្លីចំនួន០.៥១ដង ក្នុងឆ្នាំ២០២៣ សម្រាប់ទុកទូទាត់ ហើយនៅក្នុងឆ្នាំ២០២៤ បំណុលរយៈពេលខ្លីក្រុមហ៊ុនមានទ្រព្យសកម្មរយៈពេលខ្លីចំនួន០.២៧ ដង មានន័យថាក្រុម ហ៊ុនមានទ្រព្យសកម្មជិត ០.៥ ដងសម្រាប់ទុកទូទាត់។ ដូច្នេះ បើយើងពិនិត្យមើលលទ្ធភាពក្នុងការប្រើប្រាស់ ទ្រព្យសកម្មរយៈពេលខ្លីរបស់ក្រុមហ៊ុនក្នុងការទូទាត់បំណុលរយៈពេលខ្លី ឃើញថាមានចំនួនការថយចុះ ២៤% បើយើងធៀបពីឆ្នាំ ២០២៣ ទៅជាមួយនឹងឆ្នាំ២០២៤។

**ខ. អនុបាតរហ័ស ( Quick Assets Ratio)**

អនុបាតនេះ មិនរាប់បញ្ចូលសន្និធិពីទ្រព្យសកម្ម ដើម្បីទូទាត់បំណុលរយៈពេលខ្លី។ (ការមិនរាប់បញ្ចូលសន្និធិដោយមូលហេតុថា វាអាចលក់ ចេញក្នុងរយៈពេលខ្លី ឬងាយនឹងខូចខាតជាដើម) ហើយកាលណាអនុបាតនេះមានកម្រិតខ្ពស់ ក្រុមហ៊ុន កាន់តែមានស្ថានភាពហិរញ្ញវត្ថុល្អប្រសើរ ក៏ប៉ុន្តែប្រសិនបើវាមានកម្រិតទាបវិញ នោះក្រុមហ៊ុននឹងប្រឈមនូវ ផលលំបាកដូចជា ការរាំងស្ទះសាច់ប្រាក់ក្នុងការទូទាត់បំណុលរយៈពេលខ្លីរបស់ខ្លួន។

អនុបាតរហ័សមានរូបមន្តដូចខាងក្រោម៖

$$\text{Quick Assets Ratio} = \frac{\text{Quick Assets}}{\text{Current Liabilities}}$$

ដោយ (Quick Assets = Total Current Assets - Inventories)

តារាងប្រៀបធៀប

| Year | Quick Assets | Current Liabilities | Quick Assets Ratio | Change |
|---|---|---|---|---|
| 2023 | 214,653,797 | 1,046,889,852 | 0.21 | - |
| 2024 | 186,184,578 | 1,203,642,181 | 0.15 | (6%) |

បកស្រាយ ៖ យោងតាមទិន្នន័យក្នុងតារាង ខាងលើបានបង្ហាញថាផលធៀបរវាងទ្រព្យសកម្មរយៈពេលខ្លី ទៅធៀបជាមួយនឹងបំណុលរយៈពេលខ្លីក្នុងឆ្នាំ២០២៣ ស្មើនឹង ០.២១ មានន័យថាទ្រព្យសកម្មរយៈពេលខ្លីរបស់ក្រុមហ៊ុនមាន០.២១ដង នៃបំណុលរយៈពេលខ្លីសម្រាប់ទុកទូទាត់ ហើយនៅឆ្នាំ២០២៤ វិញក្នុងស្មើនឹង០.១៥ មានន័យថា ទ្រព្យសកម្មរយៈពេលខ្លីរបស់ក្រុមហ៊ុនមាន០.១៥ដង នៃបំណុលរយៈពេលខ្លីសម្រាប់ទូទាត់។ នេះបញ្ជាក់ឱ្យឃើញថា លទ្ធភាពសងបំណុលរយៈពេលខ្លី មានការថយចុះបន្ថែម ៦% បើធៀបឆ្នាំ២០២៣ ទៅនឹងឆ្នាំ២០២៤ បង្ហាញថាក្រុមហ៊ុនបានប្រឈមនឹងហានិភ័យខ្ពស់ក្នុងការទូទាត់បំណុលបន្ទាន់។

**គ. អនុបាតសាច់ប្រាក់ ( Cash Ratio )**

អនុបាតនេះ ពិចារណាតែសាច់ប្រាក់ និងសមមូលសាច់ប្រាក់ប៉ុណ្ណោះ ដើម្បីទូទាត់បំណុលរយៈពេលខ្លី។ កាលណាតួលេខ របស់អនុបាតនេះកាន់តែធំនោះ គឺវាមានលក្ខណៈល្អប្រសើរសម្រាប់ម្ចាស់បំណុលរយៈពេលខ្លី ក៏ប៉ុន្តែចំពោះអង្គភាពវិញនោះ យើងអាចធ្វើការសន្និដ្ឋានបានថាអង្គភាពមានសាច់ប្រាក់ច្រើនដែលទុកចោលឱ្យនៅទំនេរដោយមិនបានយកទៅប្រើប្រាស់ដើម្បីបង្កើននូវចំណូល របស់អង្គភាពបន្ថែមទៀត។

អនុបាតសាច់ប្រាក់មានរូបមន្តដូចខាងក្រោម៖

$$\text{Cash Ratio} = \frac{\text{Cash + Cash Equivalent}}{\text{Current Liabilities}}$$

តារាងប្រៀបធៀប

| Year | Cash + Cash Equivalent | Current Liabilities | Cash Ratio | Change |
|---|---|---|---|---|
| 2023 | 23,088,570 | 1,046,889,852 | 0.022 | - |
| 2024 | 18,406,666 | 1,203,642,181 | 0.015 | (0.7%) |

បកស្រាយ៖ យោងតាមតារាង ខាងលើបានបង្ហាញថានៅឆ្នាំ២០២៣ ផលធៀបរវាងសាច់ប្រាក់ជាមួយនឹងបំណុលរយៈពេលខ្លីក្នុងឆ្នាំ២០២៣ ស្មើនឹង០.០២២ មានន័យថាសាច់ប្រាប់មាន២.២% នៃបំណុល រយៈពេលខ្លី ហើយសម្រាប់ឆ្នាំ២០២៤ សាច់ប្រាក់ចំនួន១.៥% នៃបំណុលរយៈពេលខ្លីរបស់ក្រុមហ៊ុន សម្រាប់ទុកទូទាត់។ ដូច្នេះ បើយើងពិនិត្យមើលទៅលើការប្រើប្រាស់សាច់ប្រាក់របស់ក្រុមហ៊ុន ដើម្បីទូទាត់បំណុលរយៈពេលខ្លី ឃើញថាមានការថយចុះចំនួន០.៧% បើធៀបពីឆ្នាំ២០២៣ ទៅនឹងឆ្នាំ២០២៤។

សរុបសេចក្តីមក អនុបាតនៃលទ្ធភាពទូទាត់បំណុលរយៈពេលខ្លី របស់ក្រុមហ៊ុនរួមមាន អនុបាតចរន្ត (Current Ratio) អនុបាតរហ័ស (Quick Ratio) អនុបាតសាច់ប្រាក់ (Cash Ratio) មានការថយចុះ គួរឱ្យកត់សម្គាល់បើធ្វើការប្រៀបធៀបពីឆ្នាំ២០២៣ ទៅនឹងឆ្នាំ២០២៤។

**៣.២.២ អនុបាតនៃលទ្ធភាពទូទាត់បំណុលរយៈពេលវែង ( Solvency ratio )**

ការប្រើប្រាស់វិធីសាស្រ្តវិភាគ ដោយពឹងផ្អែកតាមអនុបាតនៃលទ្ធភាពទូទាត់បំណុលរយៈពេលវែងនេះ គឺប្រើប្រាស់ដើម្បីវាស់វែងនូវកំរិតជាប់បំណុលរបស់អង្គភាព ហើយវាក៏បង្ហាញអំពីសម្ថភាពរបស់អង្គភាពក្នុងការសងបំណុលរយៈពេលវែងផងដែរ ដោយការប្រើប្រាស់តាមការគណនាជាមួយនឹងរូបមន្តនីមួយៗដែលមាន ដូចខាងក្រោម៖

**ក. អនុបាតបំណុលសរុប ( Total Debt Ratio )**

អនុបាតបំណុលត្រូវបានកំណត់ជាសមាមាត្រនៃ បំណុលសរុបទៅនឹងទ្រព្យសកម្មសរុប ដែលបង្ហាញជាទសភាគ ឬភាគរយ។ វាអាចត្រូវបានបក ស្រាយថាជាសមាមាត្រនៃទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនដែលត្រូវបានផ្តល់ហិរញ្ញប្បទានដោយបំណុល។ ជាទូទៅបើអនុបាតនេះធំជាង១ មានន័យថាអង្គភាពមានបំណុលច្រើនជាងទ្រព្យ ក៏ប៉ុន្តែបើអនុបាតនេះតូច ជាង១ វិញនោះអង្គភាពមានទ្រព្យច្រើនជាងបំណុល។ រីឯម្ចាស់ក្រុមហ៊ុនវិញ គឺចង់ឱ្យក្រុមហ៊ុនរបស់ខ្លួនប្រើ បំណុលនេះកាន់តែច្រើន ពីព្រោះថាវាអាចជួយបង្កើនប្រាក់ចំណេញរំពឹងទុករបស់ពួកគេ។ ដូច្នេះ អ្នកគ្រប់គ្រងត្រូវបានសម្រេចចិត្តលើកម្រិតបំណុលដែលក្រុមហ៊ុនគួរប្រើប្រាស ជៀសវាងកុំឱ្យបង្កើនហានិភ័យនៃការពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទូទាត់បំណុលវិញ។

រូបមន្តអនុបាតបំណុលសរុបមានដូចខាងក្រោម៖

$$\text{Total Debt Ratio} = \frac{\text{បំណុលសរុប (Total Debt)}}{\text{ទ្រព្យសរុប (Total Assets)}}$$

ដោយៈ ( Total Debt = Total Current Liabilities + Total Non-Current Liabilities)

តារាងប្រៀបធៀប

| Year | Total Debt | Total Assets | Total Debt Ratio | Change |
|---|---|---|---|---|
| 2023 | 1,753,769,386 | 3,038,365,177 | 0.57 | - |
| 2024 | 1,914,092,668 | 3,279,165,281 | 0.58 | 1% |

បកស្រាយៈ តាមទិន្នន័យនៅក្នុងតារាង ខាងលើបានបង្ហាញថានៅឆ្នាំ២០២៣ ផលធៀបរវាង បំណុលសរុបជាមួយនឹងទ្រព្យសកម្មសរុបស្មើនឹង០.៥៧ មានន័យថារាល់ ១ពាន់រៀល នៃទ្រព្យសកម្មសរុបដែល ក្រុមហ៊ុនមាន ក្រុមហ៊ុនបានប្រើប្រាស់បំណុលចំនួន៥៧% ហើយនៅឆ្នាំ២០២៤រាល់ ១ពាន់រៀល នៃទ្រព្យ សកម្មសរុបដែលក្រុមហ៊ុនមាន ក្រុមហ៊ុនបានប្រើប្រាស់បំណុលចំនួន៥៨%។ ដូច្នេះយើងពិនិត្យឃើញថា ការប្រើប្រាស់បំណុល របស់ក្រុមហ៊ុនមានការកើនឡើងគួរឱ្យកត់សម្គាល់ចំនួន១% បើធ្វើការធៀបចាប់ពីឆ្នាំ២០២៣ ទៅនឹងឆ្នាំ២០២៤។ ការកើនឡើងនៃអនុបាតសរុបបានបញ្ជាក់ឱ្យ ឃើញថាការប្រើប្រាស់បំណុលរបស់ក្រុមហ៊ុននៅក្នុងឆ្នាំ២០២៤ មានការកើនឡើងធៀបទៅនឹងឆ្នាំ២០២៣។

**ខ. អនុបាតបំណុលធៀបនឹងមូលធន ( Debt/Equity Ratio )**

អនុបាតនេះនឹងបង្ហាញថា តើក្នុងមួយដុល្លារនៃមូលធនរបស់ក្រុមហ៊ុនបានខ្ចីគេប៉ុន្មានដុល្លារដើម្បីទិញទ្រព្យ។ កាលណាអនុបាតបំណុលធៀបនឹងមូលធននេះមានការកើនឡើងនោះ គឺវានឹងបានបង្ហាញថា ក្រុមហ៊ុនកំពុងតែប្រើប្រាស់បំណុលច្រើនដើម្បីវិនិយោគទៅលើទ្រព្យ។

រូបមន្តអនុបាតបំណុលធៀបនឹងមូលធនមានដូចខាងក្រោមៈ

$$\text{Debt/Equity Ratio} = \frac{\text{បំណុលសរុប (Total Debt)}}{\text{មូលធនសរុប (Total Equity)}}$$

ដោយៈ ( Total Debt = Total Current Liabilities + Total Non-Current Liabilities)

តារាងប្រៀបធៀប

| Year | Total Debt | Total Equity | Debt/Equity Ratio | Change |
|---|---|---|---|---|
| 2023 | 1,753,769,386 | 1,284,595,791 | 1.37 | - |
| 2024 | 1,914,092,668 | 1,365,072,613 | 1.40 | 3% |

បកស្រាយៈ តាមតារាង ខាងលើបានបង្ហាញថានៅឆ្នាំ២០២៣ ផលធៀបរវាងបំណុលសរុប ធៀបនឹងមូលធនសរុបស្មើនឹង១.៣៧ មានន័យថា ក្រុមហ៊ុនប្រើប្រាស់បំណុលរួមជាមួយមូលធនចំនួន១៣៧% ហើយ

នៅក្នុងឆ្នាំ២០២៤ ក្រុមហ៊ុនប្រើប្រាស់បំណុលរួមជាមួយមូលធនចំនួន ១៤០%។ ដូច្នេះ បើយើងពិនិត្យមើលលើការប្រើប្រាស់បំណុលរួមជាមួយមូលធនរបស់ក្រុមហ៊ុន គឺឃើញថាវាមានការកើនឡើងគួរឱ្យកត់សម្គាល់ គឺចំនួន៣% បើធ្វើការប្រៀបធៀបពីឆ្នាំ២០២៣ ទៅនឹងឆ្នាំ២០២៤។

**គ. មេគុណមូលធន &Equity Multiplier '**

Equity Multiplier នឹងបង្ហាញអំពីការប្រើប្រាស់បំណុលរបស់ក្រុមហ៊ុន ដើម្បីវិនិយោគទៅលើ ទ្រព្យសកម្ម (Assets)។ ជាទូទៅប្រសិនបើ មេគុណមូលធនរបស់ក្រុមហ៊ុនមានការកើន ឡើងខ្ពស់នោះវានឹងបង្ហាញថាក្រុមហ៊ុនកំពុងតែប្រើប្រាស់បំណុលច្រើន ដើម្បីវិនិយោគទៅលើទ្រព្យសកម្ម ផ្ទុយពីនេះវិញប្រសិនបើក្រុមហ៊ុនមានមេគុណមូលធនទាបវិញនោះ វាមានន័យថាស្ថានភាពហិរញ្ញវត្ថុរបស់ ក្រុមហ៊ុនមាន ដំណើរការល្អប្រសើរដោយមិនសូវពឹងផ្អែកលើបំណុលច្រើន។

រូបមន្តមេគុណមូលធនមានដូចខាងក្រោម៖

$$\text{Equity Multiplier} = \frac{\text{ទ្រព្យសរុប (Total Assets)}}{\text{មូលធនសរុប (Total Equity)}}$$

តារាងប្រៀបធៀប

| Year | Total Assets | Total Equity | Equity Multiplier | Change |
|---|---|---|---|---|
| 2023 | 3,279,165,281 | 1,365,072,613 | 2.40 | - |
| 2024 | 3,038,365,177 | 1,284,595,791 | 2.37 | (3%) |

បកស្រាយ ៖ តាមទិន្នន័យដែលបានបង្ហាញនៅក្នុងតារាង ខាងលើនៅឆ្នាំ២០២៣ ផលធៀបរវាង ទ្រព្យសកម្មសរុបធៀបនឹងមូលធនសរុបស្មើនឹង២.៤០ មានន័យថាទ្រព្យសកម្មសរុបស្មើជិត៣ដងនៃមូល ធនសរុប ហើយក្នុងឆ្នាំ២០២៤ វិញផលធៀបនេះមានចំនួន២.៣៧ មានន័យថាទ្រព្យសកម្មសរុបស្មើនឹង៣ដង នៃមូលធន ដូច្នេះតាមរយៈផលធៀបទាំងនេះ យើងសង្កេតឃើញថាមានការថយចុះចំនួន៣% បើធ្វើការប្រៀបធៀបពីឆ្នាំ២០២៣ ទៅនឹងឆ្នាំ២០២៤។

**៣.២.៣ អនុបាតនៃលទ្ធភាពស្វែងរកប្រាក់ចំណេញ ( Profitability ratio )**

ការវិភាគដោយពឹងផ្អែកតាមអនុបាតនៃលទ្ធភាពស្វែងរកប្រាក់ចំណេញ (Profitability Ratios) នេះវានឹង បង្ហាញអំពីសម្ថភាពរបស់ក្រុមហ៊ុនក្នុងការស្វែងរកប្រាក់ចំណេញពីសកម្មភាពអាជីវកម្មរបស់ខ្លួនបានល្អដែរឬទេ ដោយប្រើប្រាស់ការគណនាតាមរូបមន្តនីមួយៗដែលមានដូចខាងក្រោម៖

**ក. អនុបាតចំណេញដុល ( Profit Margin )**

អនុបាតនេះ ឆ្លុះបញ្ចាំងពីសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបង្កើតប្រាក់ចំណូលបន្ទាប់ពីការចំណាយ និងពន្ធទាំងអស់ត្រូវបានគណនា។ វាត្រូវបានទទួលដោយបែងចែកប្រាក់ចំណូលសុទ្ធទៅជាចំណូលសរុប។ កាលណាបើអនុបាតនេះកាន់តែធំនោះ គឺកាន់តែល្អសម្រាប់ក្រុមហ៊ុនពីព្រោះវាបានបង្ហាញថា ក្រុមហ៊ុនទទួលបានប្រាក់ចំណេញកាន់តែច្រើនពីសកម្មភាពអាជីវកម្មរបស់ខ្លួន។

អនុបាតចំណេញដុលមានរូបមន្តដូចខាងក្រោម៖

$$\text{Profit Margin} = \frac{\text{ចំណេញពិត (Net Income)}}{\text{ការលក់សរុប (Total Sales)}}$$

តារាងប្រៀបធៀប

| Year | Net Income | Total Sales | Profit Margin | Change |
|---|---|---|---|---|
| 2023 | 72,647,572 | 333,408,830 | 0.22 | - |
| 2024 | 85,042,913 | 347,697,778 | 0.24 | 2% |

បកស្រាយ ៖ តាមតារាង ខាងលើបានបង្ហាញឱ្យឃើញថានៅឆ្នាំ២០២៣ ក្រុមហ៊ុនមានកម្រិត ប្រាក់ចំណេញ០.២២ ស្មើរនឹង២២% ហើយឆ្នាំ២០២៤ វិញ ក្រុមហ៊ុនមានកម្រិតប្រាក់ចំណេញ ០.២៤ ស្មើ រនឹង២៤%។ ដូច្នេះ យើងសង្កេតឃើញថា ក្រុមហ៊ុនមានប្រាក់ចំណេញកើនឡើង២% បើធៀបពីឆ្នាំ២០២៣ ទៅ នឹងឆ្នាំ២០២៤។

**ខ. អនុបាតនៃចំណេញលើទ្រព្យសកម្ម ( Return on assets )**

ប្រាក់ចំណេញ ត្រូវបានវាយតម្លៃទាក់ទងទៅនឹងការចំណាយ និងការចំណាយ។ វាត្រូវបានវិភាគដោយប្រៀបធៀបទៅនឹង ទ្រព្យសកម្ម ដើម្បីមើលថាតើក្រុមហ៊ុនមានប្រសិទ្ធភាពយ៉ាងណាក្នុងការពង្រាយទ្រព្យសកម្មដើម្បីបង្កើតការលក់ និងប្រាក់ចំណេញ។ កាលណាអនុបាតនេះកាន់តែធំ គឺវាកាន់តែល្អសម្រាប់ក្រុមហ៊ុន ពីព្រោះវាបានបង្ហាញពីប្រសិទ្ធភាពនៃការប្រើប្រាស់ទ្រព្យសកម្មរបស់ក្រុមហ៊ុនក្នុងការបង្កើតប្រាក់ចំណេញកាន់តែល្អប្រសើរ។

អនុបាតនៃចំណេញលើទ្រព្យមានរូបមន្តដូចខាងក្រោម៖

$$\text{Return on assets} = \frac{\text{ចំណេញពិត (Net Income)}}{\text{ទ្រព្យសកម្មសរុប (Total Assets)}}$$

តារាងប្រៀបធៀប

| Year | Net Income | Total Assets | Profit Margin | Change |
|---|---|---|---|---|
| 2023 | 72,647,572 | 3,038,365,177 | 0.023 | - |
| 2024 | 85,042,913 | 3,279,165,281 | 0.025 | 0.2% |

បកស្រាយ ៖ តាមទិន្នន័យដែលបង្ហាញនៅក្នុងតារាង ខាងលើនៅឆ្នាំ២០២៣ ការប្រើប្រាស់ទ្រព្យសកម្ម ក្រុមហ៊ុនអាចបង្កើតប្រាក់ចំណេញបានត្រឹមតែ០.២៣% ហើយនៅក្នុងឆ្នាំ២០២៤ វិញ ការប្រើប្រាស់ទ្រព្យ សកម្ម ក្រុមហ៊ុនអាចបង្កើតប្រាក់ចំណេញបាន០.២៥%។ ដូច្នេះហើយបើយើង ពិនិត្យមើលទៅលើការ

ប្រើ ប្រាស់ទ្រព្យសកម្មរបស់ក្រុមហ៊ុន ដើម្បីអាចបង្កើតប្រាក់ចំណេញបាន គឺឃើញថាមានការកើនឡើងបន្តិច គឺចំនួន០.២% បើធ្វើការធៀបចាប់ពីឆ្នាំ២០២៣ ទៅនឹងឆ្នាំ២០២៤។

**គ. អនុបាតចំណេញលើមូលធន ( Return on equity )**

អនុបាតនេះ ត្រូវបានគេវាស់វែងពីទំនាក់ទំនងរវាងបំណុលសរុប (Total liabilities) និងទ្រព្យសកម្ម សរុប (Total assets)។ ប្រសិនបើអនុបាតនេះកាន់តែធំ គឺវាកាន់តែល្អសម្រាប់ក្រុមហ៊ុន ពីព្រោះវាបានបង្ហាញ អំពីសមត្ថភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់មូលធនរបស់ក្រុមហ៊ុនក្នុងការបង្កើតប្រាក់ ចំណេញបាន កាន់តែល្អប្រសើរ។

អនុបាតចំណេញលើមូលធនមានរូបមន្តដូចខាងក្រោម៖

$$\text{Return on equity} = \frac{\text{ចំណេញពិត (Net Income)}}{\text{ដើមទុនសរុប (Total Equities)}}$$

តារាងប្រៀបធៀប

| Year | Net Income | Total Equities | Return on Equity | Change |
|---|---|---|---|---|
| 2023 | 72,647,572 | 1,284,595,791 | 0.057 | - |
| 2024 | 85,042,913 | 1,365,072,613 | 0.062 | 0.5% |

បកស្រាយ៖ តាមតារាង ខាងលើបានបង្ហាញថានៅឆ្នាំ២០២៣ មូលធនក្រុមហ៊ុន អាចបង្កើត ប្រាក់ចំណេញបានចំនួន០.៥៧% និងឆ្នាំ២០២៣វិញ មូលធនក្រុមហ៊ុនអាចបង្កើតប្រាក់ចំណេញបាន០.៦២%។ ដូច្នេះ យើងពិនិត្យឃើញថា ការប្រើប្រាស់មូលធនរបស់ក្រុមហ៊ុន ដើម្បីបង្កើតប្រាក់ចំណេញ គឺឃើញថាមានការកើនឡើងបន្តិចចំនួន០.៥% បើធៀបពីឆ្នាំ២០២៣ ទៅនឹងឆ្នាំ២០២៤។

សរុបជារួមមកយោងតាមការគណនា និងបានសិក្សាលើអនុបាតនៃលទ្ធភាពក្នុង ការស្វែងរកប្រាក់ចំណេញ (Profitability Ratios) នីមួយៗខាងលើរួចមក យើងសង្កេតឃើញថានៅឆ្នាំ២០២៤ លទ្ធភាពនៃការបង្កើតប្រាក់ចំណេញការប្រើប្រាស់ទ្រព្យសកម្ម និងមូលធនមានការកើនឡើងគួរឱ្យកត់សម្គាល់ ដូច្នេះ ហើយយើងអាចសន្និដ្ឋានបានថា សមត្ថភាពដែលស្វែងរកប្រាក់ចំណេញរបស់ក្រុមហ៊ុនមានការកើនឡើងបើធ្វើ ការប្រៀបធៀបជាមួយឆ្នាំ២០២៣។

## ៣.៣ ផលប្រយោជន៍នៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

### ៣.៣.១ លទ្ធផលប្រតិបត្តិការ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PPWSA) មានតួនាទី ដ៏សំខាន់ក្នុងការផ្គត់ផ្គង់ទឹកស្អាត និងការធានាគុណភាពសេវាឱ្យបានប្រសើរទៅតាមការលូតលាស់ របស់ក្រុង។ ដើម្បីធានាលទ្ធភាពប្រតិបត្តិការបានយ៉ាងជោគជ័យ PPWSA បានអនុវត្តយុទ្ធសាស្ត្រជាច្រើនសម្រេចបានលទ្ធផលអស្ចារ្យទាំងផ្នែកហិរញ្ញវត្ថុបច្ចេកវិទ្យា

និងសេវាអតិថិជន។ នេះ គឺជាទិដ្ឋភាពសំខាន់ៗ មួយចំនួនដែលរួមចំណែកដល់លទ្ធផលប្រតិបត្តិការរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ៖

**ក. ការគ្រប់គ្រងប្រតិបត្តិការមានប្រសិទ្ធភាព**

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PPWSA) បានអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទំនើប ដើម្បីធានាឱ្យមានប្រសិទ្ធភាពក្នុងការផ្គត់ផ្គង់ទឹក។ ដោយប្រើបច្ចេកវិទ្យាដូចជា GIS (Geographic Information System), SCADA (Supervisory Control and Data Acquisition) និង Smart Metering, PPWSA អាចត្រួតពិនិត្យនិងគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកបានច្បាស់លាស់។ ជាពិសេស ការកាត់បន្ថយនូវកម្រិតអត្រាបាត់បង់ទឹក (Non-Revenue Water) បានចុះច្រើនជាងអត្រាមធ្យមក្នុងតំបន់អាស៊ាន ដែលជួយបង្កើនប្រាក់ចំណូល និងបង្កើនប្រសិទ្ធភាពប្រតិបត្តិការរបស់ស្ថាប័ន។

**ខ. ការកើនឡើងនៃតម្រូវការផ្គត់ផ្គង់ទឹក**

ការរីកចម្រើននៃប្រជាជន និងសកម្មភាពសេដ្ឋកិច្ចនៅក្រុងភ្នំពេញ បាននាំឱ្យមានតម្រូវការប្រើប្រាស់ទឹកកើនឡើងជានិច្ច។ ការកើនឡើងនេះបានបង្កើនបរិមាណលក់ទឹកប្រចាំខែ និងប្រចាំឆ្នាំ។ ជារួម កំណើននេះជួយបង្កើនប្រាក់ចំណូលពីសេវាបម្រើការផ្គត់ផ្គង់ទឹក និងអនុវត្តន៍សេវាថ្មីៗដូចជា ទឹកសម្រាប់ធ្វើ ឧស្សាហកម្ម និងអាជីវកម្មធំៗ។

**គ. ការគាំទ្រពីអាជ្ញាធររដ្ឋ និងស្ថាប័នអភិវឌ្ឍន៍**

PPWSA ទទួលបានការគាំទ្រយ៉ាងសកម្មពីរាជរដ្ឋាភិបាលកម្ពុជា តាមរយៈគោលនយោបាយរដ្ឋបាលសាធារណៈ និងការចែកចាយថវិកាជាជំនួយឬប្រាក់កម្ចីឱ្យស្ថាប័ននេះអភិវឌ្ឍប្រព័ន្ធបច្ចេកទេស។ ជាពិសេស, អង្គការអភិវឌ្ឍអន្តរជាតិដូចជា ADB (Asian Development Bank), JICA (Japan International Cooperation Agency) និងបណ្តាស្ថាប័នផ្សេងទៀតបានផ្តល់ជំនួយលើផ្នែកគ្រឿងបរិក្ខារ និងបច្ចេកទេសសម្រាប់គម្រោងអភិវឌ្ឍបណ្តាញផ្គត់ផ្គង់ទឹកនានា។

**ឃ. សមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុប្រសើរ**

PPWSA មានការគ្រប់គ្រងហិរញ្ញវត្ថុយ៉ាងមានប្រសិទ្ធភាព ដោយធ្វើការចងក្រងថវិកា ត្រួតពិនិត្យការចំណាយ និងស្វែងរកលទ្ធភាពបង្កើនប្រាក់ចំណូល។ ការសន្សំថវិកា និងការបង្កើនប្រាក់ចំណេញសុទ្ធ (Net Profit) បានជួយឱ្យស្ថាប័នមានសមត្ថភាពប្រតិបត្តិការស្ថិរភាព និងអាចវិនិយោគបន្ថែមលើគម្រោងអនាគត។ ការបោះពុម្ពផ្សាយរបាយការណ៍ហិរញ្ញវត្ថុសតិប្បន្នភាព និងមានភាពច្បាស់លាស់ក៏ជួយផ្តល់ទំនុកចិត្តដល់ភាគីពាក់ព័ន្ធផងដែរ។

**ង. ការអភិវឌ្ឍបុគ្គលិក និងសមត្ថភាពវិជ្ជាជីវៈ**

ស្ថាប័នបានផ្តោតលើការអភិវឌ្ឍធនធានមនុស្ស ដោយធ្វើការបណ្តុះបណ្តាលបុគ្គលិកជាប្រចាំ ដើម្បីបង្កើនចំណេះដឹង និងជំនាញវិជ្ជាជីវៈ។ ការចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេស និងក្រៅប្រទេសសហការជាមួយស្ថាប័នអន្តរជាតិ ក៏ជួយដល់ការអភិវឌ្ឍន៍ទិសដៅវិស័យអនុវត្តជាក់ស្តែងផងដែរ។ នេះជាភាពរឹងមាំមួយដែលធ្វើឱ្យ PPWSA មានសមត្ថភាពប្រតិបត្តិការមានគុណភាពខ្ពស់ជានិច្ច។

**ច. ការវិនិយោគលើបច្ចេកវិទ្យា និងបណ្តាញចែកចាយទឹក**

PPWSA បានចំណាយវិនិយោគយ៉ាងសកម្មលើបច្ចេកវិទ្យាចាស់ទៅទំនើប ដើម្បីធានាថានៅមានសេវាផ្គត់ផ្គង់ទឹកប្រសើរឡើងជានិច្ច។ ការជួសជុលបណ្តាញបំពង់ចាស់ៗ ការបន្ថែមអាងស្តុកទឹកថ្មីៗ និងការប្រើម៉ាស៊ីនបូមទឹកខ្ពស់ៗ បានជួយដល់ការរីកចម្រើននៃសេវាកម្ម និងកាត់បន្ថយការបាត់បង់ទឹកអនាម័យ។

**ឆ. ការច្នៃប្រឌិតសេវាថ្មី និងការចូលរួមរបស់អតិថិជន**

PPWSA បានច្នៃប្រឌិតសេវាកម្មថ្មីៗ ដូចជា៖

- ការផ្តល់សេវាទឹកសម្រាប់រោងចក្រ និងអាជីវកម្មធំៗ
- កម្មវិធីឆ្លើយតបសំណូមពរនៅលើកម្មវិធីទូរស័ព្ទ (mobile apps)
- ការផ្តល់សេវាអប់រំសាធារណៈអំពីការប្រើប្រាស់ទឹកប្រកបដោយទំនួលខុសត្រូវ
- ការចូលរួមរបស់ប្រជាពលរដ្ឋបានជួយសហការនឹងស្ថាប័នក្នុងការអភិរក្សទឹក និងធានាសេវាអភិវឌ្ឍន៍យ៉ាងល្អ

**ជ. ការរួមបញ្ចូលគោលការណ៍អភិវឌ្ឍន៍ចីរភាព**

PPWSA បានចងក្រងយុទ្ធសាស្ត្រអភិវឌ្ឍន៍យ៉ាងចីរភាព ដោយផ្អែកលើគោលដៅ SDGs របស់អង្គការសហប្រជាជាតិ។ គោលដៅនេះរួមមាន៖

- ការអភិរក្សធនធានទឹកធម្មជាតិ
- ការធានាសេវាសុវត្ថិភាព និងបរិស្ថានល្អ
- ការបង្កើតការយល់ដឹងសាធារណៈអំពីការចាំបាច់នៃការប្រើទឹកប្រកបដោយប្រសិទ្ធភាព

**ឈ. សមត្ថភាពក្នុងការឆ្លើយតបនឹងវិបត្តិ**

ក្នុងកំឡុងពេលកើតមានវិបត្តិ (ដូចជា ទឹកជំនន់ ខ្វះទឹក ឬការរីករាលដាលជំងឺ) PPWSA មានផែនការជាក់លាក់ក្នុងការឆ្លើយតប។ ការរៀបចំឧបករណ៍ចាំបាច់ជាមុន ការបែងចែកផ្គត់ផ្គង់តាមតំបន់ និងការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការបញ្ជូនព័ត៌មានបានជួយស្ថាប័នធានាសេវាប្រកបដោយចំណូលចិត្ត និងសុវត្ថិភាព។

សរុបមក រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PPWSA) បានសម្រេចបានលទ្ធផលប្រតិបត្តិការដ៏ល្អប្រសើរក្នុងរយៈពេលចុងក្រោយនេះ ដោយសារប្រព័ន្ធគ្រប់គ្រងប្រកបដោយវិជ្ជាជីវៈ ការច្នៃប្រឌិតសេវាកម្ម និងការវិនិយោគលើបច្ចេកវិទ្យាទំនើប។

**៣.៣.២ វាយតម្លៃការអនុវត្តន៍**

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ គឺជាស្ថាប័នសាធារណៈស្វ័យគ្រប់គ្រងដែលមានភារកិច្ចក្នុងការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជនក្នុងក្រុងភ្នំពេញ និងតំបន់ជុំវិញ។ ការវាយតម្លៃការអនុវត្តរបស់ PPWSA អាចបែងចែកបានតាមចំណុចសំខាន់ៗដូចខាងក្រោម៖

**ក. សមិទ្ធិផល (Performance Results)**

PPWSA បានបង្កើនលទ្ធភាពផ្គត់ផ្គង់ទឹកស្អាតទៅឱ្យអតិថិជនយ៉ាងមានប្រសិទ្ធភាពជាបន្តបន្ទាប់។ ចំនួនអតិថិជនបានកើនឡើងប្រចាំឆ្នាំ ខណៈដែលសម្ពាធទឹក និងគុណភាពទឹកត្រូវបានថែរក្សានៅលំដាប់ស្តង់ដារអន្តរជាតិ។

**ខ. ប្រសិទ្ធភាព (Efficiency)**

PPWSA ត្រូវបានគេទទួលស្គាល់ថាជាស្ថាប័នមួយដែលមានការគ្រប់គ្រងល្អប្រសើរ តម្លៃដាច់ខាតទឹក (Non-Revenue Water) ត្រូវបានកាត់បន្ថយយ៉ាងមានន័យ។ ការប្រើប្រាស់ធនធានមនុស្ស និងថវិកាត្រូវបានគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាព។

**គ. ប្រសិទ្ធិផល (Effectiveness)**

ការសម្រេចគោលដៅយុទ្ធសាស្ត្ររបស់ PPWSA ត្រូវបានអនុវត្តទាន់ពេលវេលា និងមានលទ្ធភាពបំពេញតម្រូវការប្រជាជន។ ការបង្កើនបណ្តាញបំពង់ ទទួលបានលទ្ធផលជាក់ស្តែងក្នុងការឆ្លើយតបទៅនឹងកំណើនប្រជាជន។

**ឃ. ភាពត្រៀមខ្លួន និងច្នៃប្រឌិត (Innovation & Readiness)**

PPWSA បានអនុវត្តន៍បច្ចេកវិជ្ជាថ្មីៗក្នុងការតាមដានប្រព័ន្ធផ្គត់ផ្គង់ទឹក និងប្រព័ន្ធបង់ប្រាក់ឌីជីថល។ ការអភិវឌ្ឍរបស់ស្ថាប័នជាមួយនឹងបច្ចេកវិទ្យាធ្វើឱ្យការអនុវត្តកាន់តែប្រសើរ។

**ង. ភាពថ្លៃថ្នូរ និងគុណភាពសេវាកម្ម (Service Quality & Governance)**

PPWSA មានភាពថ្លៃថ្នូរលើការគ្រប់គ្រង និងមាននីតិវិធីច្បាស់លាស់ក្នុងការផ្តល់សេវាកម្ម។ តម្លៃទឹកត្រូវបានកំណត់ដោយគិតលើមូលដ្ឋានសេដ្ឋកិច្ចនិងសង្គម ដែលធានាថាប្រជាជនទទួលបានសេវាដែលអាចទទួលយកបាន។

**ច. ចំណុចប្រឈម និងសេចក្តីផ្តល់អនុសាសន៍**

ចំណុចប្រឈមរួមមាន កំណើនប្រជាជនយ៉ាងលឿន ការរីកចម្រើនទីប្រជុំជន ការកើនឡើងនៃការប្រើប្រាស់ទឹក និងសម្ពាធលើធនធានទឹក។

សេចក្តីផ្តល់អនុសាសន៍: PPWSA គួរបន្តបង្កើនការវិនិយោគក្នុងបច្ចេកវិទ្យា ការអភិវឌ្ឍធនធានមនុស្ស និងការរកមូលនិធិរយៈពេលវែង ដើម្បីធានាថានឹងអាចបំពេញតម្រូវការនាពេលអនាគតបាន។

សរុបមក PPWSA ជាស្ថាប័នសាធារណៈដែលបានបង្ហាញភាពរឹងមាំក្នុងការអនុវត្ត។ ជាពិសេស វាបានបង្ហាញពីសមត្ថភាពគ្រប់គ្រង ឆ្លើយតបចំពោះការផ្លាស់ប្តូរនានា និងអាចធ្វើជាគំរូល្អសម្រាប់អង្គភាពសាធារណៈផ្សេងទៀត។

**៣.៣.៣ ការវិនិយោគ**

ការវិនិយោគទៅលើ PPWSA ត្រូវបានគេពិចារណាយ៉ាងម៉ត់ចត់ ដោយផ្អែកលើកត្តាចម្បងៗខាងក្រោម ដែលបង្ហាញពីភាពសមរម្យនៃស្ថាប័ននេះសម្រាប់ការវិនិយោគជាធនធានឯកជន ឬអន្តរជាតិ៖

**ក. លទ្ធផលហិរញ្ញវត្ថុគួរឱ្យទុកចិត្ត**

នៅឆ្នាំ ២០២៤ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PPWSA) បានបង្ហាញលទ្ធផលហិរញ្ញវត្ថុប្រកបដោយស្ថិរភាព និងភាពជោគជ័យ។ ប្រាក់ចំណូលសរុបឈានដល់ប្រមាណ KHR 360.70 ពាន់លាន ខណៈដែលប្រាក់ចំណេញសុទ្ធស្ថិតនៅតម្លៃ KHR 124.77 ពាន់លាន។ លទ្ធផលទាំងនេះបានបញ្ជាក់ពីសមត្ថភាពរបស់ស្ថាប័នក្នុងការប្រមូលប្រាក់ចំណូលប្រកបដោយប្រសិទ្ធភាព និងទទួលបានទំនុកចិត្តពីអ្នកវិនិយោគ។

**ខ. ភាពស្ថេរភាពនយោបាយ និងការគាំទ្រពីរដ្ឋ**

PPWSA ជាស្ថាប័នសាធារណៈក្រោមការគ្រប់គ្រងដោយរដ្ឋ ប៉ុន្តែមានអត្តសញ្ញាណស្វយ័ត។ ការគាំទ្រពីអាជ្ញាធរ និងគោលនយោបាយជាតិលើការផ្គត់ផ្គង់ទឹកអនាម័យធានាបាននូវស្ថេរភាពនៃការវិនិយោគ។

**គ. ការកាត់បន្ថយ Non-Revenue Water (NRW) មានប្រសិទ្ធភាពខ្ពស់**

NRW របស់ PPWSA ត្រឹម ~៦.៣% ដែលជាតម្លៃទាបបំផុតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ កត្តានេះបញ្ជាក់ពីការគ្រប់គ្រងប្រតិបត្តិការយ៉ាងមានប្រសិទ្ធភាពដែលធ្វើឱ្យមានចំណូលពេញលេញពីទឹកដែលផលិត។

**ឃ. ការចុះបញ្ជីលើទីផ្សារហិរញ្ញវត្ថុ (CSX)**

PPWSA គឺជាស្ថាប័នលើកដំបូងដែលបង្ហាញជាសាធារណៈក្នុងទីផ្សារភាគហ៊ុនកម្ពុជា (Cambodia Securities Exchange – CSX) ចាប់ពីឆ្នាំ២០១២។ ការចុះបញ្ជីនេះបង្ហាញពីភាពប្រកបដោយតម្លាភាព និងធ្វើឱ្យការវិនិយោគមានច្បាស់លាស់បន្ថែម។

**ង. ការវិនិយោគបច្ចេកវិទ្យា និងបណ្តាញទំនើប**

PPWSA បានវិនិយោគយ៉ាងសកម្មលើបច្ចេកវិទ្យា ដូចជា SCADA, Smart Meter, GIS system និងបណ្តាញបំពង់ថ្មីៗ ដើម្បីធានាការផ្គត់ផ្គង់ទឹកមានគុណភាព និងមានប្រសិទ្ធភាពលើការគ្រប់គ្រងថ្លៃដើម។

**ច. ការគាំទ្រជាសាធារណៈ និងភាពជឿជាក់របស់អតិថិជន**

ការស្ទង់មតិ និងការចូលរួមពីសាធារណៈបង្ហាញថា PPWSA ទទួលបានការជឿជាក់ខ្ពស់ ពីសេវាកម្មទឹកស្អាត។ កត្តានេះជួយបង្កើនភាពទាក់ទាញសម្រាប់អ្នកវិនិយោគដែលចង់បញ្ចូលទុនទៅក្នុងស្ថាប័នមានកេរ្តិ៍ឈ្មោះល្អ។

**ឆ. កំណើនតម្រូវការទឹកនាពេលអនាគត**

ការលូតលាស់នៃប្រជាជននិងសេដ្ឋកិច្ចក្នុងក្រុងភ្នំពេញនឹងបន្ថែមតម្រូវការកាន់តែច្រើនលើទឹកស្អាត។ ដូច្នេះការវិនិយោគទៅលើស្ថាប័នដូចជា PPWSA គឺមានសក្តានុពលរកប្រាក់ចំណេញប្រកបដោយចីរភាព។

សរុបមក PPWSA ជាស្ថាប័នសាធារណៈមានសមត្ថភាពគ្រប់គ្រងល្អ មានលទ្ធផលហិរញ្ញវត្ថុជាក់ស្តែង មានភាពស្ថេរភាពនយោបាយ និងជួបប្រជុំតាមលក្ខខណ្ឌដែលបង្កើនទំនុកចិត្តចំពោះអ្នកវិនិយោគ។ កត្តាទាំងនេះជាផ្លូវកាត់នាំឱ្យមានការសម្រេចចិត្តវិនិយោគយ៉ាងទូលំទូលាយ និងប្រាកដ។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ចំណុចខ្លាំង និងចំណុចខ្សោយ របស់ក្រុមហ៊ុន ពិតជាមានសារៈសំខាន់បំផុតក្នុងការវាយតម្លៃ វាស់វែង ដំណើរការ និងសកម្មភាពរបស់ក្រុមហ៊ុន។ ក្រោយពីការសិក្សាស្រាវជ្រាវ និងការវិភាគរួចមក យើងសង្កេតឃើញថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នៅមានចំណុចខ្លាំង និងមានចំណុចខ្វះខាតមួយចំនួនដែលរួមមាន៖

## ៤.១ ការវិភាគលើចំណុចខ្លាំង

ក្រោយពីបានធ្វើការវិភាគទៅលើរបាយការណ៍ហិរញ្ញវត្ថុរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញរួចមកយើង គឺឃើញថាការវិភាគរបាយការណ៍ហិរញ្ញវត្ថុមានអត្ថប្រយោជន៍ជាច្រើនសំខាន់ៗសម្រាប់ក្រុមហ៊ុន បុគ្គលិក អ្នកវិនិយោគ និងភាគីពាក់ព័ន្ធផ្សេងៗ។ ចំណុចខ្លាំងសំខាន់ៗទាំងនោះមានដូចខាងក្រោម៖

១. ការកើនឡើងចំណេញសុទ្ធ (Net Income Growth): ចំណេញសុទ្ធ PPWSA បានកើន17% ក្នុងឆ្នាំ 2024 បង្ហាញថាសមត្ថភាពរកចំណេញកាន់តែល្អ និងការគ្រប់គ្រងប្រាក់ចំណេញមានប្រសិទ្ធភាព។

២. ការរក្សា និងពង្រឹងកេរ្តិ៍ឈ្មោះ (Corporate Reputation & Trust): ជាស្ថាប័នសាធារណៈ PPWSA រក្សាភាពទុកចិត្តខ្ពស់ពីសាធារណជន និងភាគីពាក់ព័ន្ធ ដោយសារភាពថ្លៃថ្នូរហិរញ្ញវត្ថុ និងប្រសិទ្ធភាពសេវា។

៣. ការកែលម្អលើអនុបាតចំណេញ (Profitability Ratios):

- Profit Margin កើន (0.22 → 0.24)
- ROA កើន (0.023 → 0.025)
- ROE កើន (0.057 → 0.062)

ការកើននេះបញ្ជាក់ថាអង្គភាពមានប្រសិទ្ធភាពក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិ និងទុន។

៤. ការវិនិយោគក្នុងបច្ចេកវិទ្យាថ្មីៗ (Technology Development): ការអភិវឌ្ឍប្រព័ន្ធ SCADA, GIS និង Smart Metering ធ្វើឱ្យប្រតិបត្តិការមានប្រសិទ្ធភាព ធានាបាននូវភាពស្របច្បាប់ និងប្រតិបត្តិការមានភាពទាន់សម័យ។

៥. ការគ្រប់គ្រងចំណាយមានប្រសិទ្ធភាព (Cost Efficiency): ទោះមានការថយចុះលើទ្រព្យសម្បត្តិបច្ចុប្បន្ន តែសមត្ថភាពរកចំណេញមិនបានប៉ះពាល់ គឺសម្គាល់ថាមានគន្លងគ្រប់គ្រងចំណាយបានល្អ។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ មានអត្ថប្រយោជន៍យ៉ាងច្រើន ដូចដែលបានបង្ហាញកន្លែងខាងលើ ប៉ុន្តែយើងក៏ត្រូវយកចិត្តទុកដាក់ចំពោះ ចំណុចខ្សោយ ដែលអាចប៉ះពាល់ដល់ ភាពជាក់លាក់ និងប្រសិទ្ធភាពនៃការវិភាគ។ ខាងក្រោមនេះជាការវិភាគលើចំណុចខ្សោយសំខាន់ៗទាក់ទងនឹងការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ៖

១. ស្ថានភាពហិរញ្ញវត្ថុខ្ចីអន់ (Weak Liquidity Position):

- Current Ratio បន្ថយពី 0.51 ទៅ 0.27
- Quick Ratio បន្ថយពី 0.21 ទៅ 0.15

បង្ហាញថា PPWSA ប្រឈមនឹងហានិភ័យក្នុងការទូទាត់បំណុលបច្ចុប្បន្ន ខណៈទ្រព្យសម្បត្តិខ្លីថយចុះយ៉ាងច្រើន។

២. ការថយចុះនៃទ្រព្យសម្បត្តិបច្ចុប្បន្ន (Decline in Current Assets): ពី 533.4 លានរៀល (2023) ទៅ 330.4 លានរៀល (2024) ខ្វះការបង្កើតប្រភពប្រាក់ខ្លីសម្រាប់ប្រតិបត្តិការ។

៣. Equity Multiplier បន្ថយ (2.40 → 2.37): បញ្ជាក់ពីការបញ្ឈប់ការប្រើប្រាស់បំណុលបន្ថែម ឬការរាំងលើឥណទាន ដែលអាចជាប្រភពធនធានសម្រាប់ការវិនិយោគនាពេលអនាគត។

៤. បំណុលខ្លីអាចក្លាយជាបញ្ហា (Short-term Debt Risk): ការមានអនុបាតហិរញ្ញវត្ថុខ្លីក្រោម១ វាជាសញ្ញាថា PPWSA អាចប៉ះពាល់ដល់សមត្ថភាពបង់ប្រាក់របស់ខ្លួននៅពេលខ្លី បើគ្មានការគ្រប់គ្រងល្អ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សា និងវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ រួចមកយើងអាចសន្និដ្ឋានបានថា ការវិភាគរបាយការណ៍ហិរញ្ញវត្ថុនេះមានអត្ថប្រយោជន៍យ៉ាងសំខាន់ចំពោះភាគីទាំងឡាយ។ វាជាឧបករណ៍សំខាន់មួយក្នុងការបង្ហាញពីស្ថានភាពហិរញ្ញវត្ថុ និងសមត្ថភាពប្រតិបត្តិការរបស់ក្រុមហ៊ុន ដែលជួយឱ្យអ្នកមានចំណាប់អារម្មណ៍ក្នុងការវិនិយោគ ឬក៏ជាអតិថិជនអាចធ្វើសេចក្តីសម្រេចប្រកបដោយជំនឿចិត្ត។

អត្ថប្រយោជន៍សំខាន់ៗរួមមានៈ

១. សមត្ថភាពរកចំណេញកាន់តែល្អ:

ការកើនឡើងនៃចំណេញសុទ្ធ និងអនុបាត ROA, ROE, Profit Margin បញ្ជាក់ថា PPWSA មានសមត្ថភាពប្រតិបត្តិប្រកបដោយប្រសិទ្ធភាព។ ស្ថាប័នអាចប្រើប្រាស់ទ្រព្យសម្បត្តិ និងទុនដើម្បីបង្កើតតម្លៃបានយ៉ាងមានប្រសិទ្ធភាព។

២. ភាពរឹងមាំលើកេរ្តិ៍ឈ្មោះ និងភាពជឿទុកចិត្ត:

PPWSA បានបន្តរក្សាកេរ្តិ៍ឈ្មោះល្អក្នុងការផ្តល់សេវាទឹកស្អាត និងបង្ហាញស្ថានភាពហិរញ្ញវត្ថុថ្លៃថ្នូរ ដែលជាធាតុបង្កើនការជឿទុកចិត្តពីសាធារណជន និងភាគីទាក់ទង។

៣. ប៉ុន្តែមានហានិភ័យផ្នែកហិរញ្ញវត្ថុខ្លី:

ការថយចុះយ៉ាងច្រើននៃ Current Ratio និង Quick Ratio បង្ហាញថាស្ថាប័នអាចមានបញ្ហានៅក្នុងការបង់បំណុលខ្លីៗ។ ភាពអន់ខ្សោយនៃសមត្ថភាពទូទាត់បណ្តោះអាសន្ន អាចប៉ះពាល់ដល់ការប្រតិបត្តិប្រចាំថ្ងៃ និងសេវាសាធារណៈ។

៤. ការថយចុះនៃទ្រព្យសម្បត្តិបច្ចុប្បន្នជាភាពគួរឱ្យព្រួយបារម្ភ:

ប្រសិនបើមិនមានផែនការសម្របសម្រួលឱ្យមានប្រភពធនធានគ្រប់គ្រាន់នោះ ហានិភ័យនៃការខ្វះប្រាក់សម្រាប់ប្រតិបត្តិការនឹងកើនឡើង។

៥. សមត្ថភាពការប្រកួតប្រជែងនៅតែគាំទ្រដោយការវិនិយោគបច្ចេកវិទ្យា:

PPWSA កំពុងវិនិយោគក្នុងប្រព័ន្ធទំនើប ដូចជា SCADA, GIS និង Smart Metering ដែលអាចជួយបន្ថយបំណុលប៉ុន្មាន និងបង្កើនភាពត្រឹមត្រូវក្នុងការគ្រប់គ្រងប្រាក់ចំណូល។

រួមសេចក្តីមក ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវ និងបានពិភាក្សាគ្នាបានយ៉ាងច្បាស់លាស់រួចមកសារណារបស់ក្រុមយើងខ្ញុំទៅលើប្រធានបទ "ផលប្រយោជន៍នៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ" ក្រុមរបស់យើងខ្ញុំក៏អាចសន្និដ្ឋានបានថា ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ ពិតជាធ្វើឱ្យក្រុមហ៊ុន មានភាពងាយស្រួល ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងកាន់តែមានភាពច្បាស់លាស់បន្ថែមទៀតទៅលើលទ្ធផល ចំណេញ ខាត ហើយវាក៏អាចជួយឱ្យ បំណុលនៅក្នុងក្រុមហ៊ុន ថយចុះផងដែរ។

## ៥.២ ការផ្តល់អនុសាសន៍

បន្ទាប់ពីបានឆ្លងកាត់នូវការធ្វើសេចក្តីសន្និដ្ឋានរួចមក"**ផលប្រយោជន៍នៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**" ក្រុមរបស់យើងខ្ញុំក៏បានយល់ច្បាស់ពីការវិភាគរបាយការណ៍ វាពិតជាមានផលប្រយោជន៍ដ៏ល្អសម្រាប់ក្រុមហ៊ុន និងអាចកាត់បន្ថយរាល់បញ្ហាដែលកើតមាន។ ប៉ុន្តែនៅពីក្រោយភាព រីកចម្រើនរបស់ក្រុមហ៊ុន យើងក៏ឃើញថានៅមានចំណុចដែលខ្វះខាតមួយចំនួនដែលក្រុមហ៊ុនត្រូវកែលម្អបន្ថែមទៀត។ ដូចនេះហើយ ក្រុមរបស់យើងខ្ញុំក៏មានមតិយោលបល់មួយចំនួន ដែលស្ថិតនៅក្នុងន័យដើម្បីធ្វើឱ្យក្រុមហ៊ុនកាន់តែមានភាពរីកចម្រើន និងគួរតែមានភាពប្រុងប្រយ័ត្នទៅលើចំណុចទាំងនេះមានដូចខាងក្រោម៖

១. ពង្រឹងស្ថានភាពហិរញ្ញវត្ថុខ្លី (Liquidity Management):

- ត្រូវបង្កើតបំណុលខ្លីបន្ថែម (Short-term Credit Line) ឬបង្កើតបរិយាបន្នភាពប្រាក់សំណព្វ (Cash Buffer)
- ការកែសម្រួលគ្រប់គ្រងឥណទាន និងការទូទាត់លើអ្នកផ្គត់ផ្គង់
- បង្កើតយុទ្ធសាស្រ្តកាត់បន្ថយចំណាយរហ័ស

២. ពង្រឹងប្រព័ន្ធគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (Financial Risk Management):

- ត្រូវដាក់ចេញគោលនយោបាយគ្រប់គ្រងបំណុល (Debt Management Policy)
- តាមដានលើសមត្ថភាពទូទាត់.ជាប្រចាំ ដើម្បីបង្ការ Defaul

៣. បន្តការវិនិយោគក្នុងបច្ចេកវិទ្យានិងបុគ្គលិក៖

- បច្ចេកវិទ្យាដូចជា AMR (Automatic Meter Reading)
- បណ្តុះបណ្តាលបុគ្គលិកក្នុងវិស័យគ្រប់គ្រងទិន្នន័យ និងវិភាគហិរញ្ញវត្ថុ

៤. ពង្រឹងភាពជឿទុកចិត្ត និងការចូលរួមសាធារណៈ៖

- បង្កើតរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆមាស/ឆ្នាំដល់សាធារណៈ
- ពង្រឹងសេវាកម្មអតិថិជន និងគាំទ្រសេវាកម្មតាមប្រព័ន្ធឌីជីថល

៥. អភិវឌ្ឍលក្ខណៈប្រកួតប្រជែងក្នុងទីផ្សារ:

- រៀបចំយុទ្ធសាស្រ្តសេវាកម្មអនាគត ដូចជា ការផ្គត់ផ្គង់ទឹកទៅតំបន់ជាយក្រុង
- បង្កើតទំនាក់ទំនងជាមួយអង្គភាពអន្តរជាតិក្នុងការសហការវិនិយោគ

ដោយអនុវត្តន៍អនុសាសន៍ខាងលើរួចមក ការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាចក្លាយជាឧបករណ៍មានប្រសិទ្ធភាពបន្ថែមសម្រាប់ការសម្រេចចិត្តហិរញ្ញវត្ថុ និងវិនិយោគ ព្រមទាំងធានាបាននូវភាពត្រឹមត្រូវ និងពេញលេញនៃព័ត៌មាន។

# ឯកសារយោង


- រៀបរៀងដោយនិស្សិត គីម ជីត្រូ, ផាន់ សុផានិត, ឌុំ ដេត, លិ ម្លិស, ភី ស៊ីណា. (ឆ្នាំ២០២៤). *ប្រធានបទ: ផលប្រយោជន៍នៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន តូយ៉ូតា.* សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ ជំនាន់ទី២១ នៃវិទ្យាស្ថាន វ៉ាន់ដា ភ្នំពេញ ទំព័រទី២១-២៨ សរុប ៣៥ទំព័រ។
- រៀបរៀងដោយនិស្សិត ម៉េង ស្រីកា, ផាន់ ហៀម, មុំ សុជីវណ្ណ, នៅ ស្រីនីត, រឿន ម៉ារ៉ា. (ឆ្នាំ២០២៣). ប្រធានបទ: *ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ.* សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ ជំនាន់ទី២០ នៃវិទ្យាស្ថាន វ៉ាន់ដា ភ្នំពេញ ទំព័រទី៣-១៧ សរុប៥៨ ទំព័រ។
- គេហទំព័រ MrOllie. Finance history. Retrieved June, 18 2025 from https://share.google/PlV3JyWZYpzvb7GYt
- គេហទំព័រ ADAM HAYES. (May 11, 2025). What Does Finance Mean? Its History, Types, and Importance Explained. Retrieved from https://www.investopedia.com/terms/f/finance.asp
- គេហទំព័រ MEAGAN DREW. (June 15, 2025). Financial Statements: List of Types and How to Read Them. Retrieved from https://www.investopedia.com/terms/f/financial-statements.asp
- គេហទំព័រ PPWSA. (2022). Phnom Penh Water Supply Authority. Retrieved from https://www.ppwsa.com.kh/en/index.php?id=503&page=newsdetail&utm_source=chatgpt.com

# ឧបសម្ព័ន្ធ



ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងតំបន់សេវាផ្គត់ផ្គង់ទឹកស្អាតនៅរាជធានីភ្នំពេញ ២០២១-២០៣០
Water Supply System And Water Supply Service Area In Phnom Penh Capital For The Period 2021-2030
* Bakheng WTP
- Production Capacity 390,000m³/d
- Construction
• Stage1 (2019-2022)
• Stage2 (2022-2023)
- WTP Operation
• Stage1 (2022)
• Stage2 (2023)
* Chroy Changwar WTP
- Production Capacity 130,000m³/d
- Construction (1998-2003)
- WTP Operation (2003)
* Phum Prek WTP
- Production Capacity 150,000m³/d
- Construction (1993-2003)
- WTP Operation (2003)
* Expansion
- Production Capacity 195,000m³/d
- Construction (2025-2026)
- WTP Operation (2026)
* Chamcar Mom WTP
- Production Capacity 52,000m³/d
- Construction (2018-2019)
- WTP Operation (2019)
* Niroth WTP
- Production Capacity 260,000m³/d
- Construction
• Stage1 (2010-2013)
• Stage2 (2014-2016)
- WTP Operation
• Stage1 (2013)
• Stage2 (2016)
* Ta Khmao WTP
- Production Capacity 30,000m³/d
- Construction (2021-2023)
- WTP Operation (2023)
* Boeng Thom WTP
- Production Capacity 5,000m³/d
- Construction (2021-2023)
National Road 1
National Road 2
National Road 3
National Road 4
National Road 5
National Road 6
National Road 21
National Road 21A
National Road 20A (104)
Scale Bar
0 1Km 3Km 5Km 10Km
Total Area
Years | Phnom Penh (Km²) | Ta Khmao (Km²)
1993 | 78 |
2006 | 382 | 32
2019 | 692 | 53
Legend
Service Area 1993
Service Area 2021
Service Area 2025
Service Area 2030
Licensed Area
Boundary Phnom Penh And Ta Khmau
Location of WTP
Water Tower
- Production Capacity WTP Total 2026 (1,062,000m³/d)
PHNOM PENH WATER SUPPLY AUTHORITY
Prepare by Planning And Project Department On January 2021




Production
Production capacity
Potential Demand
Average Production forecast
95% min
95% sup
m³/day
1 000 000
800 000
600 000
400 000
200 000
0
2000 2002 2004 2006 2008 2010 2012 2014 2016 2018 2020 2022 2024 2026 2028 2030
(195,000m³/d) Bakheng 2 - 195 MLD
(195,000m³/d) Bakheng 1 - 195 MLD
(52,000m³/d) Chamcar Mon
(130,000m³/d) Niroth 2
Ta Khmau
(130,000m³/d) Niroth 1 full
Niroth 1 partial
(65,000m³/d) Chroy Changvar 2
(100,000m³/d) CCW Energy savings
(65,000m³/d) Phum Prek extension
Chroy Changvar 1
១.០០០.០០០+ម៣/ថ្ងៃ
៨១០.០០០ម៣/ថ្ងៃ
សមត្ថភាពផលិត ៥៧០.០០០ម៣/ថ្ងៃ


Balance Sheet
- Asset
- Liability
- Equity
Income Statement
- Revenues
- Expenses
- The bottom line
Financial Statements
Statement of Cash flows
- Cash from Operating Activities
- Cash from Investing Activities
- Cash from Finacing Activities
- Net change
Statement of Changes in Equity
- Beggining Banlance
- Changes in Equity
- Net Income/Loss
- Ending Balance


តើអ្វីជារបាយការណ៍ហិរញ្ញវត្ថុ?
BIO Program
Financial Statements
តារាងតុល្យការ
របាយការណ៍លំហូរសាច់ប្រាក់
របាយការប្រាក់ចំណេញ
អត្ថប្រយោជន៍
លក្ខណៈស្តង់ដារ
ងាយស្រួលក្នុងការប្រៀបធៀប
តាមដានរបាយការណ៍
កំណត់សិទ្ធិប្រាក់កម្ចី
www.bioaccelerators.com